# ទស្សនាវដ្ដី
# សាស្ត្រាចារ្យ

ផ្សាយចេញ
រាល់ត្រីមាស
ពី


សមាគម
សាស្ត្រាចារ្យខ្មែរ

ទីស្នាក់ការ
លេខ ១៩៨ E វិថីព្រះសីហនុ ភ្នំពេញ





កក្កដា សីហា កញ្ញា

លេខ
22

# មាតិការឿង

## ស.ស.ខ. ថ្វាយព្រះពរសម្ដេចឪ


★ កិច្ចការសមាគម

. ការប្រឡងកូលមហាវិ.គរុកោសល្យ - សាលាគរុវិជ្ជាជាន់ខ្ពស់ 1

. លិខិតរបស់ ស.ស.ខ. ជូនសហ. សូណែម 3

. មហាសន្និបាតស្នើឲ្យយកភាសាជាតិ ជាយានភាសា 6

★ មហាសន្និបាតសាមញ្ញ ស.ស.ខ. ឆ្នាំ 1966 8

. សេចក្ដីរាយការណ៍ ផ្លូវចិត្ត របស់ប្រធាន 13

. សេចក្ដីរាយការណ៍ សកម្មភាព របស់អគ្គលេខាធិការ 17

. សេចក្ដីរាយការណ៍ ហិរញ្ញវត្ថុ របស់អនុហេរញ្ញិក 23

. ពិធីជប់លៀង - ភាពយន្ត 25

★ ចិត្តគរុកោសល្យ

. LE NOUVEAU PROGRAMME,
QUE NOUS APPORTE-T-IL DE NOUVEAU ? 29

★ អត្ថបទនឹងឯកសារ

. ប្រទេសខ្មែរសម័យបច្ចុប្បន្ន 33

. រុក្ខជាតិឱសថ នឹង ជីវសាស្ត្ររុក្ខជាតិ 49



ក្នុងឱកាសពិធីចំរើនព្រះជន្ម

សូម សម្តេចឪ ទ្រង់មានព្រះជន្មាយុយឺនយូរ នឹងឈ្នះមារ
សត្រូវ មានចក្រពត្រអាមេរិកាំង នឹងបរិវារទាំងអស់ ។

គណៈកម្មាធិការនាយកនៃ ស.ស.ខ



ឧត្តមសេនីយ៍ឯកពិចំរើកហាកេនីផក្ខ

រមេះម្ហូ១ទី ះម្លេនហិឃក្តូ៦ះញូនមេចំឡ្យ និ៦ម្តុះមេ មម្ហ

' ប់អមទាំរទេះមេមើម៦ទី ទាំអើមារេអត្យពត្យូមទមេ ចក្យូមេ

ទ.ហ.ហ ឧកៃមយអេរេកេណិម្លកៈណាត

# ម ញ្ញា ស. ស. ខ. ឆ្នាំ 1966

ចំណែករបស់សមាគមយើង ក្នុងការលំអការសិក្សាជាតិ មានការជំរុញនូវគំនិតខេមរនីយកម្ម នៃការសិក្សា នឹងចូលរួមក្នុងចលនាអក្ខរកម្មជាដើម ។

ដោយមិត្តខៀវ កុមារ អគ្គហេរញ្ញិក ត្រូវទៅបំពេញទស្សនកិច្ចនៅប្រទេសចិនប្រជាមានិត មិត្តឡម ពីន់ផន ហេរញ្ញិករងបានជំរាបអង្គប្រជុំថា ហិបប្រាក់របស់យើងមានសភាពនឹងនជាមធ្យម ។ ប៉ុន្តែមិត្តបានបញ្ជាក់ថា នៅមានមិត្តតំណាងខ្លះដែរ ដែលពុំទាន់បានប្រមូលភាគទានផ្ញើមកគ.នាយក ហើយមិត្តសូមអំពាវនាវ ឲ្យមិត្តទាំងនោះ រួសរាន់បំបាត់ការយឺតយ៉ាវរបស់ខ្លួន ។

(សូមអានតារាងស្ដីអំពីចំណូលចំណាយនៅខាងក្រោយ)





# ការពិភាក្សា

លុះការបោះឆ្នោត ជ្រើសរើសសមាជិកគ.នាយកថ្មី បានប្រព្រឹត្តទៅរួចហើយ ការពិភាក្សាអំពីសេចក្ដីរាយការណ៍ (ខាងផ្លូវចិត្ត ខាងសកម្មភាព និងខាងហិរញ្ញវត្ថុ) ក៏ចាប់ផ្ដើម ។ មានមិត្តជាច្រើននាក់បានឡើងធ្វើអន្តរាគមន៍ ដោយចាប់អារម្មណ៍សរសើរពីការខិតខំរបស់គ.នាយក ក្នុងការទាក់ទងនឹងសមាជិក ក្នុងការផ្ដល់វិភាគទានដល់ខេមរនិយកម្មនៃការសិក្សា ។ តែមានមិត្តខ្លះមានសេចក្ដីបារម្ភដោយឃើញសមាជិកចូលមករួមក្នុងមហាសន្និបាតមានចំនួនតិច បើប្រៀបធៀបទៅនឹងចំនួនសមាជិកទាំងអស់ ។ ចំពោះមតិនេះ មិត្តមួយចំនួនឡើងឲ្យយោបល់ថា នេះមិនមែនមកពីគេមិនចូលចិត្តមកប្រជុំនោះទេ ។ គឺម្យ៉ាងមកពីមិត្តខ្លះមានកិច្ចរវល់ផ្ទាល់ខ្លួន ម្យ៉ាងទៀតមកពីគេទុកចិត្តលើតំណាងរបស់គេ ឬប្រហែលមកពីគេមិនបានទទួលដំណឹងក៏មិនដឹង ។ តែបើប្រៀបធៀបចំនួននេះទៅនឹងសមាគមផ្សេងៗវិញ ឃើញថាមហាសន្និបាតយើងមានសមាជិកមកចូលរួមច្រើនបង្គួរដែរ ។

លទ្ធផលនៃការបោះឆ្នោត

| | | | |
|---|---|---|---|
| មិត្ត | មាស ឌឹម | ៨៤ | សម្លេង |
| — | ទៀវ កុមារ | ៨៩ | — |
| — | ទីវ អុល | ៨៥ | — |
| — | កែ គិមហួត | ៥៧ | — |
| — | ធុច រិន | ៦៥ | — |
| — | គង់ សុកឃុន | ៦៥ | — |
| — | លាង ហាប់អាន | ៦៦ | — |
| — | អ៊ឹង គឹមសេង | ៦៧ | — |
| — | ព្រុំ សំអារ | ៦៤ | — |
| — | កង សារ៉ន | ៤៣ | — |
| — | ភាម យស្សា | ៤០ | — |
| — | ស៊ឹង ភត់ | ៣៦ | — |

មិត្តម្នាក់ទៀតបានឡើងចាប់អារម្មណ៍ចំពោះការរីកចំរើននៃសមាគមយើងសព្វថ្ងៃ ទាំងខាងចំនួនសមាជិកនិងការយកចិត្តទុកដាក់របស់សមាជិកចំពោះសមាគម ហើយបានទាំងសង្កត់ធ្ងន់ថា នេះមិនមែនមកពីសមាជិកភាគច្រើនមិនដឹងមិនឮនោះទេ ព្រោះថាដំណឹងពីមហាសន្និបាតនេះ បានផ្សាយជ្រួតជ្រាបល្អណាស់ ។ រឿងនេះបណ្ដាលមកពីសមាជិកមួយចំនួនមិនទាន់យល់សមាគមនៅឡើយ ។ តែដល់ថ្ងៃក្រោយពេលសមាជិកទាំងនោះ យល់នូវបញ្ហាសមាគម

បញ្ហាចំនួនទឹងកើនឯង ៗ ចំពោះការបារម្ភខាងលើនេះ មិត្តខ្លះទៀតបានបន្ថែមថា នេះមិនមែនមកពីគេខ្លាចសមាគមយើង ថាសមាគមយើងដើរខុសផ្លូវនោះទេ ៗ បើមានអ្នកខ្លះថាយើងពណ៌នេះ ពណ៌នោះ ក៏មកពីយើងយកចិត្តទុកដាក់ការពារប្រ-យោជន៍មិត្តយើង ការពារវប្បធម៌ជាតិយើង លើកស្ទួយបញ្ហាខេមរនីយកម្មប៉ុណ្ណោះ ៗ បើយើងដើរតាមមាគ៌ាជាតិដូចនេះហើយ នៅតែមានមតិទិទៀនទៀត យើងទុកឲ្យគេទិទៀនទៅចុះ ៗ ចំពោះយើង យើងត្រូវតែដើរតាមមាគ៌ានេះតទៅទៀត ៗ

★

# សេចក្ដីសំរេចចិត្ត

មហាសន្និបាត ក្រោយដែលបានពិភាក្សាអស់ពេលដ៏យូរមក បានសំរេចជាឯកច្ឆន្ទនូវបញ្ហាតទៅនេះ :

## I. ខេមរនីយកម្ម

១– ធ្វងតាមការពិសោធន៍នៅបរទេស មហាសន្និបាត ស្នើសូមឲ្យទុកភាសាបរទេសទាំងអស់ជាជីវភាសា (Langue vivante) ហើយទុកភាសាខ្មែរ ជាយានភាសា ( Langue véhicule) ។

២– ជាបណ្ដោះអាសន្ន សូមស្នើឲ្យរៀនភូមិវិទ្យា និងប្រវត្តិវិទ្យាជាភាសាខ្មែរ ហើយវិញ្ញាសាប្រឡងចំពោះមុខវិជ្ជានេះ ក៏សូមឲ្យដាក់ជាភាសាខ្មែរផងដែរ ។

## II. មធ្យោបាយបង្កើនស្មារតីគាំទ្រសមាគម

. សូមឲ្យសមាជិកទាំងអស់មេត្តារាប់រកគ្នាដូចជាមនុស្សនៅក្នុងគ្រួសារតែមួយ ។ នៅពេលមិត្តយើងមានទុក្ខលំបាកដូចជាមានជម្ងឺជាដើម មិត្តតំណាង

គួរកៀរគរគ្នាយើងដែលនៅជិតៗ ទៅសាកសួរ ជួយឈឺឆ្អាលយកចិត្តទុកដាក់ឲ្យពេញទំហឹង ។

. នៅក្នុងអនុវិ-វិទ្យាល័យនីមួយៗ បើមានការទាស់ទែងគ្នា រវាងសាស្ត្រាចារ្យ - សាស្ត្រាចារ្យ សាស្ត្រាចារ្យ-ចាងហ្វាង បើអាចធ្វើទៅបាន គួរតែផ្សះផ្សាគ្នាតាមរយៈសមាគម ។ ធ្វើដូចនេះ ឃើញថាជា ភាគទានមួយយ៉ាងសំខាន់ ដល់សមាគមយើងដែរ ។

## III. សមាគមមរណូបត្ថម្ភ

នឹងបង្កើតឲ្យមានសមាគមមរណូ-បត្ថម្ភនៃមិត្តសាស្ត្រាចារ្យមួយ នៅក្នុងផ្ទៃនៃសមាគមយើង ដើម្បីជួយសំរាលទុក្ខសមាជិកនឹងគ្រួសារ ។

## IV. គ្រូបំពេញវិជ្ជាប្រឡងចូលមហាវិទ្យាល័យគរុកោសល្យ

សូមឲ្យគ.នាយកបន្តការទាមទារតទៅទៀត ហើយខាងសមាគមបុគ្គលិកសិក្សាក៏គួរតែជួយធ្វើការទាមទារផងដែរ ។

## V. រកដីមួយកន្លែងជាកម្មសិទ្ធិសមាគម

សូមឲ្យគ.នាយកគិតគូរ សុំដីមួយកន្លែងនៅចំការចិន ដែលរាជការបំរុងទុកឲ្យ ស.ប.ស.១ ហើយគិតគូរធ្វើឆ្នោតវត្ថុយកកំរៃសង់ទីស្នាក់ការ ។

## VI. ការផ្សាយដំណឹងពីមហាសន្និបាត

. សូមឲ្យទាក់ទងតាមសំបុត្រទៅខេត្តក្រៅឲ្យបានយូរថ្ងៃមុន មហាសន្និ-បាតបន្តិច ។

. ចុះដំណឹងនេះ តាមកាសែតពីរយ៉ាងតិច

. ផ្សាយដំណឹងតាមវិទ្យុ

មិត្ត សមាជិកទាំងឡាយបានពិភាក្សាអំពីបញ្ហាទាំងពួងយ៉ាងសុខុមក្នុងគំនិតយោគយល់គ្នា ដើម្បីឆ្ពោះទៅរកសេចក្ដីចំរើនរួមៗ មហាសន្និបាតក៏បានចប់សព្វគ្រប់ នៅម៉ោង១៣នឹង៣០នាទី គត់ក្នុងបរិយាកាសសាមគ្គី ជិតស្និទ្ធក្រៃលែង ។

# សេចក្តីរាយការណ៍ផ្លូវចិត្ត

របស់មិត្ត មាស ឌឹម ប្រធាន

មិត្តជាទីស្នេហាទាំងឡាយ !

ក្នុងនាមគណៈកម្មាធិការនាយក ខ្ញុំសូមថ្លែងនូវអំណរគុណជាពន់ពេកដល់មិត្តទាំងអស់ ដែលមានសមានចិត្ត សោមនស្សអញ្ជើញចូលមករួបរួមក្នុងមហាសន្និបាតសាមញ្ញនេះ ។ ខ្ញុំសូមជូនដល់មហាសន្និបាតនូវសេចក្តីរាយការណ៍យ៉ាងសង្ខេប ដែលត្រូវមិត្ត ទីវ អ៊ុល អគ្គលេខាធិការនឹងបំពេញទៅខាងមុខ ៖

## ១– អំពីសកម្មភាពសមាគម

ក្នុងឆ្នាំកន្លងផុតទៅនេះ គ.នាយកក្រោយពីបានទទួលអាណត្តិ របស់មិត្តទាំងអស់ ហើយ បានប្រជុំគ្នាដើម្បីសំរេចនូវគំរោងការដែលត្រូវធ្វើ ហើយបានខំប្រឹងប្រែងអស់ពីសមត្ថភាព តាមមធ្យោបាយស្តួចស្តើងដែលយើងមាន ដើម្បីសំរេចគោលបំណងនេះ គឺអនុវត្តឱ្យបានត្រឹមត្រូវនូវសេចក្តីសំរេចចិត្តរបស់មហាសន្និបាត ឆ្នាំ ១៩៦៥ ព្រមទាំងសកម្មភាពផ្សេងៗទៀត ដើម្បីធ្វើឱ្យសមាគមយើងមានដំណើរគាប់ប្រសើរ ។

## ២– ការទាក់ទងរវាងសមាជិក

គ.នាយកបានសំរេចថា នឹងចេញទៅតាមខេត្តខ្លះ ដើម្បីសួរសុខទុក្ខដល់មិត្តសមាជិកទាំងអស់ តែកិច្ចនេះយើងពុំបានសំរេចទេ ដោយហេតុយើងខ្វះមធ្យោបាយដឹកនាំ នឹងសមាជិកយើងម្នាក់ៗមានកិច្ចមមាញឹកពេកនៅឯភជធានី ។ ការទាក់ទងតាមសំបុត្រស្នាម

ក៏ពុំសូវមានដែរ តែយើងបានរៀបចំពិធីជប់លៀងនេះឡើងក៏ដើម្បីសំរេចគោលបំណងការពាក់ទងគ្នានេះ ។

## ៣– ការជួយសមាជិកតាមលក្ខន្តិកៈ

យើងបានជួយដល់សមាជិកខ្លះ តាមផ្លូវសម្ភារៈ នឹងតាមផ្លូវចិត្ត :

តាមផ្លូវសម្ភារៈ យើងបានសំរេចក្រៅលក្ខន្តិកៈថា បើសមាជិកណាមួយទទួលមរណភាព នឹងជួយ ១.០០០ រៀល បើភរិយាស្លាប់ ៥០០ រៀល ហើយឪពុក - ម្ដាយ ៣០០ រៀល ។ រហូតមក យើងបានជួយឪពុកមិត្ត តុំ ស៊ុនដារ៉ា នៅស្លូង នឹងថ្មីៗនេះភរិយាមិត្ត ប៉េង សេង នៅកំពង់ត្របែក ។

គ.នាយកពុំបានព្រងើយកន្តើយ ក្នុងការអនុវត្តសំរេចនូវគោលបំណងលក្ខន្តិកៈទេ គឺបានគិតដល់ប្រយោជន៍សមាជិក មានការតវ៉ាជាច្រើនលើក ច្រើនគ្រា សុំឲ្យ៖

ក– សាស្ត្រាចារ្យណាដែលមានតែ Diplome មានសិទ្ធិប្រឡងចូលមហាវិទ្យាល័យគរុកោសល្យបាន ហើយអ្នកដែលជាប់ Bacc I បានចូលតែម្ដងជាដើម . . .

ខ– សាស្ត្រាចារ្យចេញពីមហាវិទ្យាល័យគរុកោសល្យ ហើយដែលគ្មាន Propédeutique មានសិទ្ធិប្រឡងចូលសាលាគរុកោសល្យវិជ្ជាជាន់ខ្ពស់ ។ យើងបានតវ៉ាដោយសំបុត្រ ដោយញត្តិ ដោយទៅជួបផ្ទាល់នឹងសកលវិទ្យាធិការជាដើម តែរហូតមកដល់ថ្ងៃនេះពុំបានសំរេចសោះទេ ដោយអ្នកអង្គម្ចាស់ទេសរដ្ឋមន្ត្រី បានកែប្រែទំរង់សាលានោះអស់ :

– ទំរង់ការសិក្សា ( មានតែឆ្នាំទី ២ )

– ទំរង់អាហារូបករណ៍ ( បន្ថយនឹងឲ្យតែអ្នកណាដែលក្រ )

– កិច្ចសន្យារវាងខ្មែរ - បារាំង ( សាលាគរុវិជ្ជាជាន់ខ្ពស់ )

ចំពោះបញ្ហាទី ២ យើងអាចធ្វើបានដោយទាក់ទងផ្ទាល់នឹងសមាគមនិស្សិតមហាវិទ្យាល័យអក្សរសាស្ត្រ បង្កើត Cours de correspondance ដើម្បីឲ្យមិត្តនៅឆ្ងាយ ៗ មានសម្ភារៈនឹងសិក្សាបានផង ។

យើងមានបំណងរៀបចំឲ្យមានមរណូបត្ថម្ភអមសមាគមយើង ជួយដល់មិត្ត ដែលបានទទួលមរណភាព ហើយជាមធ្យោបាយទាក់ទងឲ្យសាស្ត្រាចារ្យយើង មានចិត្តជាប់ជំពាក់នឹងសមាគមផង ។

## ៤- កិច្ចគាំទ្រដល់នយោបាយ ខាងក្រៅសមាគម

យើងតែងតែធ្វើញត្តិទៅថ្វាយសម្ដេចឪ ដើម្បីគាំទ្រព្រះរាជនយោបាយព្រះអង្គ មានការថ្វាយសព្ទសាធុការពរចំពោះព្រះមាតាជាតិ នឹងចំពោះសម្ដេចសង្ឃរាជទាំង២គណៈផង ។

ដោយមិត្តយើងម្នាក់មានឋានៈជានាយកវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ យើងក៏បានទាក់ទងយ៉ាងជិតស្និទ្ធ ហើយមិត្តទាំងអស់អាចទៅខ្ចីសៀវភៅគ្រប់បែបយ៉ាង ដើម្បីសិក្សាដោយស្រួល ។

## ៥– កិច្ចទាក់ទងខាងក្រៅប្រទេស

រហូតមក យើងពុំទាន់មានការទាក់ទង នឹងសមាគមបរទេសបែបយើងនេះឲ្យស្រួលទេ ។ មានតែសាស្ត្រាចារ្យនៅប្រទេសចិនប្រជាមានិត ដែលយើងតែងជូនពរនៅពេលបុណ្យឯករាជ្យគេ នឹងលទ្ធផលនៃបណ្ឌិតចិនដែលបានយកជ័យជំនះ ពីពួកមហាអំណាចខាងលិច ក្នុងការបង្កើតគ្រាប់បែកបរមាណូជាដើម ។

យើងបានទទួលអញ្ជើញពី Ligue internationale des Enseignants នៅប្រទេសបារាំងដែរ តែដោយយើងគ្មានសោហ៊ុយ ក៏ពុំបានចូលរួមក្នុងមហាសមាជគេ នៅក្រុង Paris ។

## ៦- បញ្ហាទស្សនាវដ្ដី

ទស្សនាវដ្ដីយើង ជាអង្គការផ្សាយដំណឹងពីដំណើរសមាគម និងជាអង្គការសិក្សាលើកដំកើងវិជ្ជាជីវៈរបស់យើងផង ។ ដោយសមាជិកយើងមានកិច្ចរវល់ច្រើនពេក ហើយសមត្ថភាពក៏អន់ថយផង អត្ថបទក៏ពុំសូវមានតម្លៃសមដល់គោលបំណងនេះ ។ ត្រង់ចំណុចនេះ សូមអំពាវនាវដល់សមាជិកដែលមានគំនិតល្អៗមេត្តាជួយសរសេរដើម្បីបង្រៀនដើម្បីជួយប្ដូរយោបល់ដល់សមាជិកឯទៀតៗផង ។ មកពីហេតុដូចនេះ បានជាទស្សនាវដ្ដីយើងចេះតែរអាក់រអួលណាស់ដែរ ។

## ៧- ស្មារតីសមាគម

តាមសេចក្ដីសង្កេតឃើញថា កំរិតស្មារតី មិត្តសាស្ត្រាចារ្យយើង មិនបានឡើងខ្ពស់ជាងពីមុនៗទេ ។ ហេតុនេះ សូមមិត្តមេត្តាជួយរកមធ្យោបាយដើម្បីអនុវត្តទៅមុខ ។


បណ្ណាគារ វិជ្ជាសាកល
257 មហាវិថីព្រះសីហនុ ភ្នំពេញ

បណ្ណាគារ សុភមិត្រ
367 C ផ្លូវកម្ពុជាក្រោម ភ្នំពេញ

បណ្ណាគារទាំង ២ នេះ នឹងបញ្ចុះថ្លៃ 10 % ជូនមិត្តយើង
ដែលទៅទិញ សៀវភៅខ្មែរ នៅបណ្ណាគារទាំងនេះ ។

សូមបង្ហាញបណ្ណសមាជិក !

# សេចក្ដីរាយការណ៍ សកម្មភាព

របស់មិត្ត ទីវ អុល អគ្គលេខាធិការ

តាំងតែពីមហាសន្និបាតឆ្នាំទៅ មកដល់មហាសន្និបាតរបស់យើងនាថ្ងៃនេះ មានព្រឹត្តិការណ៍ជាច្រើនបានផ្ដល់នូវផលល្អដល់ប្រទេសយើង ។ ពលរដ្ឋយើងបានរួមគ្នាជាធ្លុងមួយដង្ហែសម្ដេចឪ ដើម្បីនឹងការពារបូរណភាពដែនដីយើង នឹងឯកភាពជាតិយើង ហើយដើម្បីនឹងស្ថាបនាប្រទេសយើង ។ នៅក្នុងវិស័យសិក្សាធិការ សម្ដេចឪទ្រង់បានណែនាំឲ្យកែទម្រង់ការសិក្សារបស់យើង ឲ្យបានកាន់តែប្រសើរឡើង រីឯចលនាអក្ខរកម្មក៏មានល្បឿនទៅមុខ គួរជាទីពេញចិត្តទូទាំងប្រទេស ។

សមាគមយើង តាមសមត្ថភាពរបស់ខ្លួន បានខិតខំផ្ដល់នូវវិភាគទានដោយអស់ពីកម្លាំងកាយ កម្លាំងចិត្តនិងកម្លាំងប្រាជ្ញាដល់ការវិវឌ្ឍន៍នៃប្រទេសយើង នឹងដល់ការការពារផលប្រយោជន៍នៃមិត្តសមាជិកយើង ស្របទៅតាមគំនិតនៃលក្ខន្តិកៈយើង ។ ហេតុនេះហើយ បានជាសមាគមយើងបានជួបនឹងលក្ខណៈងាយស្រួលជាមធ្យម ក្នុងការបំពេញសកម្មភាពរបស់ខ្លួន ។

## I. ជីវភាពផ្ទៃក្នុងសមាគម

គណៈកម្មាធិការនាយកបច្ចុប្បន្នដែលបានទទួលសេចក្ដីទុកចិត្តពីមិត្តយើងមក ទោះបីបានជួបនឹងឧបសគ្គខ្លះ ៗ ដូចមិត្តយើងបានជ្រាបស្រាប់ហើយក្ដី ក៏បានដាក់ចិត្តជានិច្ចទៅលើផលប្រយោជន៍មិត្តយើង ហើយបានពុះពារទៅតាមលទ្ធភាពទាំងប៉ុន្មានដែលខ្លួនមាន ។

ក្នុងពេលនេះ យើងខ្ញុំសូមមិនរៀបរាប់ឡើងវិញនូវការទាក់ទងជាធម្មតា រវាងសមាជិកនិងគណៈកម្មាធិការនាយកទេ ទោះបីការនេះសំខាន់ដែរក្តី ដូចការផ្ញើបញ្ជីជំរឿនទៅឲ្យមិត្តយើងបំពេញ ការរំលឹកដាស់តឿនជាញឹកញាប់ឲ្យបំពេញបញ្ជីនេះ ការសាកសួរសុខទុក្ខដោយផ្ទាល់នៅមន្ទីរពេទ្យជាដើម ។ ចំណែកឯពិធីជប់លៀងជាប្រពៃណី និងការបញ្ចាំងកុនកាលពីយប់មិញបានជោគជ័យយ៉ាងណា ៗ នោះ មិត្តយើងក៏បានជ្រាបស្រាប់ហើយ ។ យើងក៏ពុំបាច់លើកយកមករាប់ដែរ ។

ចំពោះទស្សនាវដ្តីដែលកំណត់ថា ចេញ ៤ លេខក្នុងមួយឆ្នាំ យើងទើបតែនឹងចេញបាន ៣ ប៉ុណ្ណោះទេ ឯលេខ ៤ កំពុងតែនៅក្នុងរោងពុម្ពសព្វថ្ងៃនៅឡើយ ។ មូលហេតុមានពីរយ៉ាង : ម្យ៉ាងជាមូលហេតុធម្មតា គឺការខ្វះខាតអត្ថបទប្រកបដោយសារសំខាន់ ឯមូលហេតុម្យ៉ាងទៀត គឺការដែលមិត្តក្នុងគណៈកម្មាធិការនាយកបីនាក់ ដែលកាន់កាប់ទស្សនាវដ្តីនេះត្រូវផ្លាស់ ហើយដែលជះឥទ្ធិពលមកលើការចេញទស្សនាវដ្តីនេះ ។

អាស្រ័យការខិតខំម្យ៉ាងទៀតរបស់សមាគមយើង សមាគមយើងទើបតែនឹងបានពង្រីកបណ្ណាល័យរបស់ខ្លួន ដោយពុទ្ធសាសនបណ្ឌិតធ្វើអំណោយដល់សមាគមយើងនូវសៀវភៅចំនួនជាង ១០០ ក្បាល ដែលវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត បានបោះផ្សាយ ។

ពេលនេះ យើងខ្ញុំសូមបញ្ជាក់តែពីសកម្មភាពបួន ដែលមានប្រយោជន៍ជាប់ជិតស្និទ្ធនឹងមិត្តយើង គឺ :

១– ការជួយទុក្ខធុរៈ ក្រៅពីសំណូមពីឆ្នាំទៅ

២– ការទាមទារ ដើម្បីឲ្យសមាជិក បានប្រឡងចូល សាលាគរុវិជ្ជាជាន់ខ្ពស់ ។ សូមមើល :

– លិខិតផ្ញើទៅសកលវិទ្យាធិការ ចុះថ្ងៃ ២០ មករា ១៩៦៦ សូមអនុញ្ញាតឲ្យសាស្ត្រាចារ្យបឋមភូមិ ដែលបានធ្វើការបីឆ្នាំហើយ ឲ្យមានសិទ្ធិប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់ ។

– មកដល់ថ្ងៃ ២៧ មករា លោកសាកលវិទ្យាធិការ បានឆ្លើយថា លោកគ្មានយោបល់ជំទាស់ទេ ប៉ុន្តែ ចំពោះ ខ នេះ កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងរដ្ឋាភិបាលបារាំងបានអនុញ្ញាត «តែបេក្ខជនណា ដែលមានបុព្វសិក្សាបត្រ» ។

– លុះមកដល់ថ្ងៃ១៧ កុម្ភៈ ទ្រង់ទេសរដ្ឋមន្ត្រីបានបញ្ជាក់ទៀតថា ក្រសួងអប់រំជាតិមិនអាចយល់ព្រមតាមសេចក្ដីស្នើរបស់ ស.ស ខ.ទេ ព្រោះកិច្ចព្រមព្រៀងជាមួយបារាំងធ្វើឡើងក្នុងគំនិត នឹងធ្វើឲ្យសាស្ត្រាចារ្យមធ្យមក្លាយទៅជា "មនុស្សមានតម្លៃអន្តរជាតិ" ។

## ៣– ការចូលមហាវិទ្យាល័យគរុកោសល្យ

គ.នាយក ស.ស.ខ. បានផ្ញើលិខិតមួយច្បាប់ទៅលោកសាកលវិទ្យាធិការ (២៤-២-៦៦) ដើម្បីនឹងសូមឲ្យមិត្តគ្រូបង្រៀនដែលមានមធ្យមសិក្សាបត្រភាគ ២ (Stagiaire) មានសិទ្ធិចូលរៀនថ្នាក់សាស្ត្រាចារ្យដោយពុំបាច់ប្រឡង ហើយដោយបានទទួលបៀវត្សដដែល ។ ចំពោះគ្រូមានមធ្យមសិក្សាបត្រភាគ ២ ចាប់ពីថ្នាក់ទី ៤ ទៅ សូមតាំងជាសាស្ត្រាចារ្យតែម្ដងតាមសមាមាត្រនៃបៀវត្ស ។

ចំពោះសេចក្ដីស្នើរបស់យើងនេះ ទ្រង់ឆ្លើយកាលពីថ្ងៃ ១៩-៣-៦៦ ថាទ្រង់ពុំអាចទទួលបានទេ ព្រោះមិនស្របនឹងនយោបាយ « désengagement » របស់រាជរដ្ឋាភិបាល ។

## ៤– ករណីនៃមិត្តគ្រូបង្រៀនបំពេញវិជ្ជា DC, Bac I, Bac II,

ចំពោះខនេះ គណៈកម្មាធិការនាយកយើងបានផ្ញើលិខិតមួយច្បាប់ថ្វាយសម្ដេចព្រះប្រមុខរដ្ឋ ដើម្បីនឹងសូមព្រះរាជានុញ្ញាត

. ឲ្យគ្រូថ្នាក់បំពេញវិជ្ជា (DC) មានសិទ្ធិប្រឡងចូលរៀនធ្វើសាស្ត្រាចារ្យ ;

. ឲ្យគ្រូមានមធ្យមសិក្សាបត្រភាគ ១ មានសិទ្ធិប្រឡងចូលរៀន ដោយរក្សាទុកបៀវត្សដដែល ;

. ឲយសាស្ត្រាចារ្យមានមធ្យមសិក្សាបត្រភាគ ២ មានសិទ្ធិចូលរៀនថ្នាក់សាស្ត្រាចារ្យតែ ១ ឆ្នាំ

. ហើយឲយសាស្ត្រាចារ្យបឋមភូមិដែលធ្វើការបាន ៣ ឆ្នាំ មានសិទ្ធិប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់ ។

## II. ចំពោះបញ្ហាសិក្សា

— យើងតែងតែបានផ្សាយជាហូរហែតាមទស្សនាវដ្តីយើង នូវគំនិតឧបត្ថម្ភហើយជំរុញការកែទំរង់កម្មវិធីសិក្សារបស់យើង សមតាមព្រះរាជបញ្ញាក្រើនរំលឹកជាហូរហែរបស់សម្តេចឪយើង ។

— ដើម្បីជាភស្តុតាងបង្ហាញថា ខេមរនីយកម្មជារបស់អាចធ្វើទៅបាន យើងតែងតែចុះមេរៀនប្រវត្តិវិទ្យាជាហូរហែ ហើយបានចុះមេរៀនឯទៀតៗ ជាភាសាខ្មែរ យូរៗម្តង ព្រមទាំងបានផ្សាយនូវការពិសោធន៍ដ៏សំខាន់ៗ នៃប្រទេសជាមិត្តយើងខ្លះទៀតផង ។

— ក្រៅពីនេះ យើងបានឧបត្ថម្ភយ៉ាងសកម្មនូវចលនាអក្ខរកម្មដែលកំពុងប្រព្រឹត្តទៅពាសពេញព្រះរាជាណាចក្រ ដោយបន្តការបើកបង្រៀនជាហូរហែមក ។ ឆ្នាំនេះសិស្សអក្ខរកម្មរបស់យើងបានចេះអាន ចេះគិតលេខល្មម ហើយបានប្រឡងជាប់វិញ្ញាបនបត្រចំនួន ៦ នាក់ ក្នុងលើកទី ១ ។

## III. ចំពោះការទាក់ទងនឹងឥស្សរជនខ្មែរ ហើយនឹងសមាគមដទៃ

១— យើងបានផ្ញើញត្តិថ្វាយសម្តេចឪ សូមទ្រង់បន្តព្រះតំណែងជាព្រះប្រមុខរដ្ឋតទៅទៀត ។

២— បានថ្វាយញត្តិសម្តេចឪ ក្រាបបង្គំទូលពីការប្រឆាំងនឹងការមួលបង្កាច់របស់រដ្ឋបាលបាងកក នឹងកាសែត «តៃម» នឹង «អាត្លង់ទិច» ។

សម្ដេចឪទ្រង់បានចាត់ឲ្យ សហ. ប៉ៅ សេង ឆ្លើយតប ( មិត្ត ទី អុល អានសេចក្ដីឆ្លើយតប )

៣– បានផ្ញើសេចក្ដីបដិសេធមួយច្បាប់ទៅកាសែត «តែម» និង “អាត្លង់ទិច” ហើយមួយច្បាប់ទៀតទៅវិទ្យុជាតិ ដើម្បីសូមផ្សាយ ។

៤– បានសន្ទនាជាមួយអ្នកតំណាងនៃសហពន្ធអប់រំអន្តរជាតិ ។

៥– បានផ្ញើកាតតាន ១.០០០រៀល ទៅ ឯ ខ. ប្រធានរដ្ឋសភាដើម្បីសំរាលទុក្ខយុទ្ធជនទៅព្រំដែន ។

ឯ ខ. អ៊ឹង ហុងសាធ ឆ្លើយតប ( មិត្ត ទី អុល អានចម្លើយ ) ។

៦– បានជូនពរទៅសហជីពអ្នកអប់រំចិន ក្នុងឱកាសបុណ្យខួបទី ១៦ នៃការតាំងសាធារណរដ្ឋប្រជាមានិតចិន ។

មិត្តខាងនោះក៏បានឆ្លើយតបមកវិញហើយ ។

៧– ក្នុងឱកាសចូលឆ្នាំថ្មី បានថ្វាយព្រះពរជាប្រពៃណី :

– ថ្វាយសម្ដេចព្រះមហាក្សត្រិយានី

– ថ្វាយសម្ដេចឪ

– ថ្វាយសម្ដេចព្រះសំឃរាជ ទាំងពីរគណៈ ។

VI. បញ្ហាខ្លះ ៗ

តាមសេចក្ដីស្នើរបស់មិត្តសមាជិកផង និងតាមគំរោងរបស់គណៈកម្មាធិការនាយកផង ខ្ញុំសូមស្នើនូវបញ្ហាមួយចំនួនជូនមិត្តដោះស្រាយ ប្រយោជន៍នឹងធ្វើឲ្យសមាគមយើង កាន់តែមានដំណើររីកធាត់ធំតទៅទៀត កាន់តែខ្លាំងឡើងៗ ។

១— ទឹកចិត្តសមាជិកចំពោះសមាគម

សូមមិត្តជួយពិនិត្យមើលទឹកចិត្ត នៃសមាជិកចំពោះ ស.ស.ខ. យើង ហើយរកវិធីយ៉ាងណាឲ្យការផាប់ចិត្តមានកាន់តែខ្លាំងឡើង ៗ ក្នុងការផ្តល់ភាគទាន ក្នុងការទាក់ទងគ្នា ក្នុងការឈឺចាប់ជួយសង្គ្រោះគ្នា ក៏ដូចជាការផ្តល់អត្ថបទទស្សនាវដ្តី ។

២— ការប្រមូលភាគទាន

សូមមិត្តប្រមូលឲ្យបានទៀងទាត់រៀងរាល់ខែ ដើម្បីចៀសវាងទឹកលុយឡើងចំនួនច្រើនពេក នាំឲ្យមានផលវិបាកទៅលើថវិកាផ្ទាល់ខ្លួន និងទៅលើទឹកចិត្ត ។

៣— អង្គការមរណបត្តម្ភ

គ.នាយកយល់ឃើញថា អង្គការមរណបត្ថម្ភនាំឲ្យយើងមានមធ្យោបាយទាក់ទង លើកទឹកចិត្តសង្គ្រោះគ្នាបានយ៉ាងសក្តិសិទ្ធិ ហើយក៏បានត្រៀងលក្ខន្តិកៈបែកគ្នាពិនិត្យ ឲ្យយោបល់រួចស្រេចហើយ នៅតែផ្ញើទៅជូនមិត្តសំរេចតែប៉ុណ្ណោះទេ ។

★

អាស្រ័យឥរិយាបថដ៏ត្រឹមត្រូវរបស់យើង ដែលឈរនៅលើតែប្រយោជន៍ជាតិ និងប្រយោជន៍សមាជិក ហើយដែលឈរនៅលើការស្អាតស្អំ ព្រមទាំងអាស្រ័យការខិតខំប្រឹងរបស់គ.នាយកផង់នឹងការឧបត្ថម្ភរបស់មិត្តផង សមាគមយើងបានស្គាល់នូវជោគជ័យមួយជាទីពេញចិត្ត ។ យើងសង្ឃឹមថា ស.ស.ខ. យើង ក្រោមការណែនាំរបស់គ.នាយកថ្មី នឹងកាន់តែប្រមូលបាននូវលទ្ធផលដ៏ប្រសើរថែមទៀត ជាប្រាកដ ។

ជយោ វប្បធម៌ជាតិ !

# សេចក្ដីរាយការណ៍ ហិរញ្ញវត្ថុ

របស់មិត្ត ឌិម វ៉ាន់ដន អនុហេរញ្ញិក

## កំណត់របស់ ទ. សាស្ត្រាចារ្យ :

ក្នុងមហាសន្និបាត មិត្ត ឌម វ៉ាន់ដន អនុហេរញ្ញិក បានធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពហិរញ្ញវត្ថុ ក្នុងនាមមិត្ត ទៀវ កុមារ អគ្គហេរញ្ញិក ដែលកាលនោះ កំពុងតែជាប់ប្រជុំសន្និសីទវិទ្យាសាស្ត្រឯប្រទេសចិន ។ ពេលនោះ មិត្តអនុហេរញ្ញិកបានចែកជូនមិត្តតំណាង នឹង មិត្តសមាជិកនានា នូវសេចក្ដីរាយការណ៍ខាងចំណូល ចំណាយ សំណាល់ យ៉ាងល្អិតល្អន់ នឹងយ៉ាងវែង។ សេចក្ដីរាយការណ៍នេះ គឺជាសេចក្ដីស្រង់ប្រាក់ភាគទានរបស់សាលានានា ដែលមានចុះផ្សាយក្នុង "ស្ថានភាពហិរញ្ញវត្ថុ" នៃទស្សនាវដ្ដីយើងលេខមុនៗ រួចមកហើយ ហើយនឹងសេចក្ដីបន្ថែមអំពីការចំណាយសព្វគ្រប់ថែមទៀត ។

ដោយសេចក្ដីរាយការណ៍នេះវែងពេក យើងសូមអញ្ជើញមិត្តទាំងអស់ មេត្តាពិនិត្យប្រាក់ចំណូល ក្នុងទស្សនាវដ្ដីលេខមុនៗ សំរាប់ឆ្នាំនេះចុះ ហើយយើងសូមចុះផ្សាយក្នុងទីនេះ តែសេចក្ដីសារុបទូទៅអំពីចំណូល ចំណាយ នឹងសំណាល់ ដែលត្រូវបញ្ឈប់បញ្ជីនៅថ្ងៃ១២-៧.៦៦។

| | | | | |
|---|---|---|---|---|
| ក– | ចំណូល | (ពីថ្ងៃ ៩-១០-៦៥ ដល់ ១២-៧-៦៦) | 93.090 | រៀល |
| | | សល់នៅក្រៅធនាគារ (ឆ្នាំមុន) | 7.000 | – |
| | | សារុប | 100.090 | – |
| ខ– | ចំណាយ | ចំណាយទាំងអស់ | 71.956 | – |
| គ– | សំណាល់ | | 28.134 | – |

ក្នុងឆ្នាំមុន យើងបានទិញបណ្ណធនាគារអស់ ៥០.០០០ រៀល ដែលបានកំរៃ ៤ % ។ ឆ្នាំនេះយើងបានយកទៅដាក់នៅក្នុងធនាគារ (ថ្មី) ចំនួនប្រាក់ ១០.០០០ រៀល ។

ដូចនេះ សព្វថ្ងៃយើងផ្ញើនៅក្នុងធនាគារចំនួនប្រាក់ ៨៤.៩១៨ រៀល ហើយនៅសល់ទំនេរ ដើម្បីប្រើប្រាស់ខាងក្រៅចំនួន ១៨.១៣៤ រៀល ។

★

ខាងក្រោមនេះ គឺជាប្រាក់ភាគទានដែលយើងបានទទួលក្នុងថ្ងៃទី ១២-៧-៦៦ ។ រីឯភាគទានមកដល់ក្រោយថ្ងៃនេះ យើងនឹងចុះក្នុងទស្សនាវដ្ដីលេខក្រោយៗតទៅទៀត ។

| | | | |
|---|---|---|---|
| ១— | វិទ្យាល័យព្រះមុនីវង្ស (បាត់ដំបង) | 1400 + 700 | រៀល |
| ២— | ទីបាត់ការមធ្យមសិក្សា | 1.080 | — |
| ៣— | អនុវិទ្យាល័យ ព្រះសីហនុរាជ (កណ្ដាល) | 640 | — |
| ៤— | — ព្រៃដើមថ្នឹង | 500 | — |


បណ្ណាគារ គីម គី

លេខ 95 វិថីព្រះយុគន្ធរ ភ្នំពេញ

បណ្ណាគារ គីម សេង

លេខ 223 មហាវិថីព្រះមុនីវង្ស ភ្នំពេញ

មានសេចក្ដីរីករាយនឹងបញ្ចុះថ្លៃ 20% ជូនសមាជិកនៃ ស.ស.ខ. ដែលទៅទិញ សៀវភៅខ្មែរ នៅបណ្ណាគារទាំងនេះ ។

សូមបង្ហាញប័ណ្ណសមាជិក



# ពិធីជប់លៀង-ភាពយន្ត ថ្ងៃ 6-8-66

ពិធីជប់លៀងជាពិធីប្រពៃណីមួយរបស់សមាគមយើង ៗ ក្នុងឱកាសប្រឡងសញ្ញាប័ត្រលើកទី២ឆ្នាំនេះ ក៏ដូចជាក្នុងឱកាសដដែលនៃឆ្នាំមុនៗដែរ គ.នាយក ស.ស.ខ បានរៀបចំពិធីជប់លៀងមួយ ក្នុងគោលបំណងរឹតចំណងសាមគ្គីរវាងមិត្តយើង ដែលការងាររៀងខ្លួនបានបំបែកឲ្យបែកនៅឆ្ងាយៗពីគ្នា តាមតំបន់ផ្សេងៗ ក្នុងរាជាណាចក្រទាំងមូល ៗ

ពិធីជប់លៀងឆ្នាំនេះ មានសភាពថ្មីច្រើនយ៉ាង ៗ ចំនួនមិត្តយើងប្រមាណជិត ២០០នាក់ ដែលបានធ្វើឲ្យបន្ទប់សាលសមាសិក្សានៃមហាវិទ្យាល័យគរុកោសល្យតឹងតួរសម បង្កើតជាសភាពថ្មីម្យ៉ាង ៗ ថ្មីម្យ៉ាងទៀត គឺបរិយាកាសសប្បាយរីករាយ ក្នុងពិធីជប់លៀង ៗ កាលពីឆ្នាំមុនៗ យើងជប់លៀងនៅភោជនីយដ្ឋានចិន ដែលក្នុងពេលទទួលទានយើងពុំចាំបាច់ធ្វើអ្វីប៉ុន្មាន ក្រៅពីបញ្ចូលម្ហូប ឬ ភេសជ្ជៈ ៗ ប៉ុន្តែពីរឆ្នាំហើយ គឺឆ្នាំទៅ និងឆ្នាំនេះ យើងចាត់ចែងខ្លួនឯង បំរើខ្លួនឯង ទទួលទានក៏ខ្លួនឯងទៀត ៗ ការរៀបចំពិធីជប់លៀងបែបនេះ ធ្វើឲ្យចំណេញច្រើន (សោហ៊ុយតិច - សប្បាយក្នុងមិត្តភាពច្រើន) ថ្មីត្រង់តែនាំឲ្យអ្នកចាត់ចែង មានលោកគ្រូ អ្នកគ្រូ ព្រមទាំងភរិយាមិត្តយើងខ្លះ ហត់កំលាំងគួរសម – គ.នាយកសូមឆ្លៀតយកឱកាសនេះ ដើម្បីជូននូវសេចក្ដីសរសើរ និងអំណរគុណដ៏ស្មោះ ៗ



កំប៉ុន្តែ សភាពថ្មីពិសេសជាងគេ ក្នុងពិធីជប់លៀងឆ្នាំនេះ គឺពិធីបញ្ចាំងភាពយន្ត ដែលបានប្រព្រឹត្តទៅ បន្ទាប់ពីការជប់លៀង នៅក្នុងសាលសហសិក្សាដដែល ។ ជប់លៀងរួច ជញ្ជូនតុ ចាន ឆ្នាំង ទុកមួយកន្លែងរួច បង្វិលកៅអីបែរទៅរកសំពត់សចងភ្ជាប់នៅជញ្ជាំងរួច ពន្លត់ភ្លើងភ្លាម កុនក៏ចាប់បញ្ចាំង ។

ខ្សែកុនទី ១ ធ្វើឲ្យផ្ទុះសំណើចពុំស្ងប់ស្ងាត់សោះ ។ តើមិនឲ្យសើចឯណាបាន បើព្រះអាទិត្យ ព្រះពាយ ព្រះពិរុណ ដែលមនុស្សជាន់ដើម ហើយសម័យឥឡូវនេះ ក៏មានមនុស្សខ្លះដែរ ធ្លាប់បាននឹងកំពុងតែគោរពគោតក្រែង សំពះបួងសួងយ៉ាងទន់ទាប បែរជាត្រូវយកមកបង្ហាញថា មានកម្លាំងទន់ខ្សោយសោះឲ្យតែមនុស្សរួបរួមគ្នា ហ៊ានវាយបង្ក្រាបផ្ចាញ់ឲ្យស្លុតបូតមានបែបបទ ?

តែខ្សែកុនទី ២ ដែលមានចំណងជើងថា " សង្គ្រាមអាភៀន " បែរទៅជាធ្វើឲ្យមិត្តយើងស្ងាត់មាត់ឈឹង - ឈឹង ព្រោះរួលក្នុងចិត្ត ខឹង ក្តៅ... តើនរណាមួយ ទ្រាំមិនសំរក់ទឹកភ្នែកបាន ចំពោះទណ្ឌកម្មអយុត្តិធម៌ ដែលធ្លាក់ទៅលើមន្ត្រីស្លូតត្រង់ មានកំហុសព្រោះតែស្នេហាជាតិ ប្រឆាំងដាច់ខាតនឹងចក្រពត្តិបរទេស ដែលយកអាភៀនមកបំពុលជាតិរបស់ខ្លួន ? តើនរណាមិនខឹង មិនក្តៅក្រហាយនឹងមន្ត្រីទុច្ចរិត ដែលស៊ីគ្រលុំជាមួយចក្រពត្រប្រឌិតរឿងបន្តុះបង្ខូចទទេ ៗ ពីមនុស្សស្លូតត្រង់ ? ប៉ុន្តែខ្សែកុនបានបង្ហាញជាបញ្ចប់

នូវចក្រពត្រអង់គ្លេស ដែលគ្រាន់តែឈានជើងកន្លុកចូលមកលុកលុយប្រទេសគេមិនទាន់ស្រួលបួលផង ក៏ត្រូវប្រជាជននាំគ្នាពេមគ្រប់ទិសទី វាយសម្លាប់ទទឹងទទែងកាប់ក្បាលមិនអស់ ។

ចប់ខ្សែកុនទី ២ មិត្តខ្លះស្មានថា ការបញ្ចាំងកុនចប់ហើយ ប៉ុន្តែខ្សែកុនទី ៣ ចាប់បន្តទៅទៀត ។ ម្តងនេះ គឺជាខ្សែកុនឯកសារខាងវិទ្យាស្បង់ ដើរតួដោយសត្វកង្កែប កញ្ចាញ់ចេក គីង្គក់ នឹងមិត្តភក្តិរបស់គេ ។ អ្នកស្រុកយើងច្រើនមានទំលាប់ទុកសត្វកង្កែប នឹងគ្រួសារគេថាជាអ្នករំខានត្រចៀក ឬសំរាប់តែអាំងទឹងតាំ ឬក៏សំរាប់តែធ្វើជានុយស្ទូចត្រីតែប៉ុណ្ណោះ... ។ ប៉ុន្តែ ខ្សែកុនបែរជាបង្ហាញថា ចំពោះកសិកម្ម កង្កែប គីង្គក់ មានប្រយោជន៍ធំណាស់ ធំល្មមនឹងឲ្យអ្នកស្រែយើងយកចិត្តទុកដាក់ ការពារចិញ្ចឹមទៅវិញ ។ បានជាដូចនេះ ពីព្រោះការវះពោះកង្កែបតូចល្មមមួយមើល បានប្រាប់ឲ្យដឹងថា ក្នុងមួយយប់កង្កែបនីមួយៗស៊ីសត្វល្អិត មានដង្កូវជាដើម បានរហូតដល់ទៅចំនួន ៨០ ។ ចុះបើអាធំៗហើយក្នុងមួយស្រែ ៗ បើមានវាច្រើនគួរសមវិញនោះ ? ការពិសោធន៍បានបញ្ជាក់ថា ទោះជាមេអំបៅ ដង្កូវ ឬ សត្រូវតូចធំប៉ុនណា មកពីលើអាកាស មកតាមទឹក តាមដីយ៉ាងណា ក៏កង្កែប គីង្គក់ នឹងជនរួមជាតិគេហ៊ាន "មៅ" ទាំងអស់ ហ៊ានធានាថា មាតុភូមិស្រែរបស់គេនឹងនៅតែស្រស់បំព្រង់ខៀវស្រងាត់ដដែល ។

ជយោ កង្កែប គីង្គក់ កញ្ចាញ់ចេក នឹងក្រុមគ្រួសារ !

★

បើប្រៀបធៀបពិធីជប់លៀងឆ្នាំនេះ ទៅនឹងឆ្នាំមុនៗ ថ្វីបើការចាត់ចែងនៅមានខ្វះចន្លោះខ្លះក៏ដោយ ក៏គេសង្កេតឃើញថាមានការកែកាយសប្បាយ – សប្បាយមានន័យខ្លឹមសារ – ច្រើនជាងឆ្នាំមុនៗ ។ ជោគជ័យទាំងនេះ ពិតជាកើតមកពីការឈឺឆ្អាលរបស់មិត្ត

យើងពល់រូប ដែលជាបញ្ញើសក្នុងការផ្សាយដំណឹងអញ្ជើញមិត្ត ក្នុងការរៀបចំលំអបន្ទប់ រៀបតុកៅអី លាងជូតកែវចាន ជួសម្ហូបចំណី... ព្រមទាំងមកពីសមាគមមិត្តភាពខ្មែរ-ចិន ដែលមានសេចក្ដីសប្បុរស ឲយយើងខ្ចីម៉ាស៊ីនបញ្ចាំងកុន និងខ្សែកុន «សង្គ្រាមអាកៀន» ហើយដែលយើងសូមឆ្លៀតយកឱកាសនេះ ដើម្បីសំដែងនូវសេចក្ដីអំណរគុណដ៏ជ្រាលជ្រៅ របស់យើង ។



## តុល្យភាពហិរញ្ញវត្ថុនៃពិធីជប់លៀង ក្នុងឱកាស
## មហាសន្និបាត ថ្ងៃសៅរ៍ ៦ សីហា ១៩៦៦

| | | |
|---|---|---|
| ១. បំណូល | (ម្នាក់ ១០០ រៀល): | ១៥.២០០ រៀល |
| ២. បំណាយផ្សេងៗ : | | ១៥.១៨០ – |
| | ម្ហូបចំណី | ៩.៣៥០ រ |
| | ភេសជ្ជៈ | ៤.៦១០ រ |
| | បច្ចេកទេសកុន | ៣០០ រ |
| | តុបតែង | ១០០ រ |
| | កំភល | ១២០ រ |
| | កម្មករ | ៣០០ រ |
| | បង្ហា ៣ | ៤០០ រ |
| ៣. សំណល់ : | | ២០ – |



### LE NOUVEAU PROGRAMME,

# QUE NOUS APPORTE-T-IL DE NOUVEAU ?

par TES SARAVOUTH

Le sujet anime déjà des conversations et son importance mérite sans doute l'intérêt qu'il suscite.

Le grand public se doute que des changements vont avoir lieu dans notre système d'enseignement et que sous peu un nouveau programme sera mis en application. Au fait, les responsables ont déjà reçu l'orde d'élaborer un programme plus approprié pour l'Enseignement Secondaire, compte tenu des conjonctures actuelles du pays.

L'on sait que le programme de l'Enseignement Secondaire en cours répond à un besoin urgent de scolarisation, lequel vise essentiellement à donner à l'élève un minimum de culture générale qui lui permettrait de suivre avec fruit les études supérieures ou si l'élève le voulait, d'embrasser une carrière subalterne qui n'exige pas de spécialisation. Ainsi, si les jeunes gens qui ont pu terminer les études secondaires-ils ne sont d'ailleurs pas très nombreux-parviennent plus ou moins à faire leur chemin, ceux qui, pour diverses raisons, ne peuvent achever ces études, se trouvent de plus en plus dans une situation difficile parce que n'arrivant pas à s'employer comme ils l'auraient souhaité. Chacun sait quel malaise un tel état de chose a pu engendrer, et on se demande avec amertume quelle pourrait être la solution à tous ces problèmes. Sujet fort complexe, sans doute, puisqu'il touche notre jeunesse tout entière et, par voie de conséquence

l'avenir même de notre Kampuchea. C'est dans le cadre de ce vaste problème que le Gouvernement Royal a jugé opportun de réformer notre système d'enseignement, et pour commencer, de concevoir un nouveau programme pour l'Enseignement Secondaire, lequel est incontestablement la phase cruciale de l'ensemble du système. Nous nous permettons ici de rendre un profond et respectueux hommage à l'Unique et Illustre Personne, Samdech Chef de l'Etat, qui a daigné donner l'impulsion à ce nouveau pas qui ne manquera pas de faire date dans l'histoire.

Ainsi donc, un nouveau programme verra le jour. Comme tout ce qui est nouveau, il sera censé être plus approprié, mieux conçu, bref, meilleur que l'ancien. C'est alors qu'on se pose ces questions : Sera-t-il réellement meilleur que l'ancien ? Qu'est ce qu'il nous apporte de nouveau ?

A cela, nous pouvons répondre sans hésiter par l'affirmative. Il aura été meilleur parce qu'il sera mieux conçu, parce qu'il tiendra compte des facteurs sociaux et économiques du pays, de ses besoins, de ses carences; parce qu'il tiendra compte des facteurs humains, des aptitudes intellectuelles de chacun comme de ses possibilités matérielles. Il sera au demeurant, à la hauteur du niveau de l'évolution du pays et ne souffrera pas d'anachronisme. Certes, nous ne soutenons pas qu'il sera sans défaut. Une voiture, un avion, comme tout autre machine perfectionnée, aussi minutieusement étudié soit-il, souffre toujours de petites imperfections techniques et, avant d'être un instrument parfait, ne saurait éviter des mises au point successives. Il en est de même de notre programme qui, quand il sera appliqué, montrera sans doute des lacunes imprévisibles qu'il faudra combler.

Disons tout d'abord que l'application de ce nouveau programme implique l'utilisation d'un matériel et d'un personnel plus diversifiés. Cela entraîne naturellement des frais d'équipement pour le matériel et de formation pour le personnel, frais qui conditionnent le succès du programme.

Ces considérations mises à part, le nouveau programme nous paraît assez prometteur. Le nombre d'heures hebdomadaire restant sensiblement le même qu'avec le programme actuel, la réduction des heures des disciplines théoriques nous soulage d'une appréhension fort légitime : le

bourrage de crâne. Dans toutes les classes, on notera que l'éducation physique et les activités pratiques accaparent à elles seules entre cinq et six heures par semaine, si bien que sur un maximun de trente deux heures, il ne reste plus que vingt six ou vingt sept heures réservées aux disciplines dites théoriques. De telles dispositions, nous le pensons, restent dans les limites du raisonnable et les efforts intellectuels qui seront demandés aux élèves ne sauraient dégénérer au bourrage de crâne.

Ce programme comporte seulement six années d'études alors que celui qui est encore en vigueur en comporte sept. Cette réduction qui intervient dans le facteur temps pourrait encore donner lieu à une incertitude dans l'esprit de quiconque veut établir une équivalence entre l'ancien et le nouveau programme. Avec ce dernier, la scolarité est certes plus courte, mais son niveau n'est pas inférieur et ce, grâce à un excellent atout qui compense indiscutablement la différence de durée. En effet, le programme prévoit une orientation à partir de la classe de quatrième. Après avoir fait la cinquième, chaque élève peut opter entre trois sections :

1— La section « Sciences Humaines » ( ou section A ) qui met l'accent sur la formation linguistique et plus tard, sur la littérature et les Sciences humaines proprement dites.

2— La section « Sciences Technico-Mathématiques » (ou section B) qui se rattache à l'étude des Mathématiques.

3— La section « Sciences Agronomiques et Expérimentales » ( ou section C ) dont l'objet principal est l'étude des Sciences expérimentales.

Ces dispositions ont l'avantage de placer les élèves assez tôt chacun dans son élément avec des mesures appropriées d'orientation. Ainsi orientés, ces élèves vont pouvoir travailler avec fruit en exploitant à fond leurs dispositions naturelles. L'on imagine avec quel rythme, ils franchiront les étapes et quand ils auront terminé leurs études secondaires, ils n'auront certainement rien à envier à leurs camarades qui ont travaillé avec l'ancien programme. Combien d'entre nous ont été brillants en langue et gênés par les Mathématiques ou par la Physique ou la Chimie ? Après avoir obtenu leur baccalauréat, que leur est-il resté, sinon un vague souvenir, une notion plus ou moins floue de Mathématiques, de Physique ou de Chimie, qui, pour la plupart des cas ne peut servi

en aucune façon ? Donc, certaines de ces heures de Mathématiques, de Physique ou de Chimie n'auraient-elles pas été plus profitables si elles avaient été destinées aux autres disciplines qui correspondaient mieux à nos aptitudes ? La même remarque est valable pour ceux qui ont peu de goût pour les Lettres et qui, par contre montrent une nette propension à l'étude des Mathématiques ou des Sciences.

A part le gain de temps que nous venons d'exposer, l'orientation permet de former, conformément à l'esprit du programme, des éléments beaucoup plus aptes à entrer dans la vie à la sortie du lycée. Ceux qui sortiront de la section Technico— Mathématique par exemple, pourront, s'ils le désirent, trouver un emploi de dessinateur, de mécanicien ou tout autre emploi comportant plus ou moins de spécialisation sans avoir à entrer dans une école professionnelle. Ceux qui sortiront de la section Sciences Agronomiques et Expérimentales, pourront s'employer par exemple, comme aide-chimistes ou si le cœur leur en dit, créer une entreprise privée dans laquelle ils mettront à profit leur compétence technique acquise au lycée.

Ainsi donc, le nouveau programme vise à donner en même temps aux élèves une culture générale, une connaissance technique et professionnelle selon la section qu'ils choisissent.

Reconnaissons que le projet est vaste et que tout ne marchera pas comme sur des roulettes. Il n' y a pas de rose sans épine. De même, il faut une piste plus solide et plus longue, du kérosène et non de l'essence ordinaire pour faire voler un avion à réaction, plus confortable et plus rapide ; de même il faut un matériel plus approprié pour l'application du nouveau programme. Cela ne vient pas du jour au lendemain, mais cela viendra.

★

ខេមរបណ្ណាគារ

លេខ 174 វិថីខេមរភូមិន្ទ ភ្នំពេញ

មានសេចក្ដីរីករាយនឹងបញ្ចុះថ្លៃ 15 % ជូនមិត្តយើងណាដែល

ទៅទិញសៀវភៅខ្មែរ នៅបណ្ណាគារនេះ ។

សូមបង្ហាញបណ្ណសមាជិក !



# វត្ថុបទ & ឯកសារ

## ប្រវត្តិវិទ្យា

**ប្រទេសខ្មែរ សម័យបច្ចុប្បន្ន**

ដោយ ម៉ៃ លង់

### I. ប្រទេសខ្មែរ នៅក្រោមអាណាព្យាបាលបារាំង (១៨៦៣ – ១៩៥៣)

#### ក– បុព្វហេតុនៃអន្តរាគមន៍បារាំងមកក្នុងប្រទេសកម្ពុជា

បុព្វហេតុបីជាសំខាន់ ដែលជំរុញបារាំងឲ្យធ្វើអន្តរាគមន៍មកក្នុងប្រទេសខ្មែរ និងបណ្ដាប្រទេសទាំងអស់នៅឧបទ្វីបឥណ្ឌូចិន គឺបុព្វហេតុខាងសេដ្ឋកិច្ច បុព្វហេតុខាងយុទ្ធសាស្ត្រ និងបុព្វហេតុខាងវប្បធម៌ ។

១– បុព្វហេតុខាងសេដ្ឋកិច្ច : យើងបានឃើញរួចមកហើយថា ចាប់តាំងពីសតវត្សទី ១៨មក នៅទ្វីបអឺរ៉ុប មានការលូតលាស់រីកចំរើនយ៉ាងឆាប់រហ័សខាងសេដ្ឋកិច្ច ដោយសារការប្រើប្រាស់នូវឧបករណ៍បង្កើតផលថ្មី គឺម៉ាស៊ីន (សូមអាន : មេរៀនមុនឧស្សាហកម្ម) ។

ដូច្នេះ នយោបាយរកទីតាំងអាណានិគម នឹងនយោបាយស្វែងរកផ្សារ ដើម្បីលក់ទំនិញដែលត្រូវបានផលិតយ៉ាងសំបូរណ៍ហូរហៀរ ក្នុងរោងចក្រនៃបណ្ដាប្រទេសនៅទ្វីបអឺរ៉ុប បានជំរុញឲ្យមហាអំណាចអាណានិគមទាំងនោះ រកយកគ្រប់ទីកន្លែង ឬភូមិភាគណាដែលសល់ទំនេរពុំទាន់មានម្ចាស់ ពិសេសនៅអាហ្វ្រិក និងអាស៊ី ។

ប្រទេសកម្ពុជា ដែលជារដ្ឋមួយតូចនៅកណ្ដាលឧបទ្វីបឥណ្ឌូចិន ក៏ពុំអាចគេចផុតពីចលនានៃការរកអាណានិគម ដែលកំពុងមានសន្ទុះយ៉ាងខ្លាំងនោះដែរ ។

២– បុព្វហេតុខាងយុទ្ធសាស្ត្រ : ឥណ្ឌូចិនបារាំងសែសដែលមានប្រទេស ៥ ជាសមាជិក (ខ្មែរ លាវ កូសាំងស៊ីន អណ្ណាម នឹងតុងកឹង) ក្នុងសម័យនោះ គឺមានឯកភាពខាងភូមិសាស្ត្រ ។ យ៉ាងណាមិញ ប្រទេសនីមួយៗ ត្រូវបានចាត់ទុកជាមូលដ្ឋាន ឬជាស្ពានសំរាប់បង្ក្រាបនូវគ្រប់ចលនាបះបោរ ដែលផ្ទុះក្នុងប្រទេសឯទៀត ។ អាស្រ័យហេតុនេះ ទើបបារាំងរកយកមួយម្ដង ៗ នូវគ្រប់ប្រទេសទាំងអស់ ក្នុងឧបទ្វីបឥណ្ឌូចិន គឺ កូសាំងស៊ីន(ឆ្នាំ១៨៥៩) ប្រទេសកម្ពុជា (ឆ្នាំ ១៨៦៣) ប្រទេសអណ្ណាម (ឆ្នាំ១៨៨៣) ប្រទេសតុងកឹង (ឆ្នាំ១៨៨៤) ហើយជាក្រោយបំផុតគឺប្រទេសលាវ (ឆ្នាំ១៨៧៩-១៨៩៥)។

៣– បុព្វហេតុខាងវប្បធម៌ : ការឈ្លានពានខាងសេដ្ឋកិច្ចនិងទឹកដី ត្រូវតែបានបង្គ្រប់ដោយការឈ្លានពានខាងវប្បធម៌ថែមទៀត ។ បារាំងបានបញ្ចូលក្នុងគ្រប់ប្រទេសដែលធ្លាក់ចូលក្នុងនឹមរបស់ខ្លួន នូវវប្បធម៌របស់គេ ដែលច្រើនតែជាវប្បធម៌ក្លែងក្លាយប្រាសចាកពីវប្បធម៌ដើមផង ហើយពុំបានយកចិត្តទុកដាក់ថែរក្សា ឲ្យតម្លៃដល់វប្បធម៌ជាតិឡើយ ។ ក្នុងសម័យនោះ អនក្ខរភាព គឺជាលក្ខណៈទូទៅនៃប្រជាជនយើង លើកលែងតែមន្ត្រីមួយចំនួនតូចនិងព្រះសង្ឃចេញ ។ កេរ្តិ៍ដំណែលនៃវប្បធម៌ជាតិ ដែលត្រូវបានថែរក្សាទុកតាំងពីដើមមក ដោយសារព្រះមហាក្សត្រ និងវត្តអារាមរបស់យើង ក៏ត្រូវមហាអំណាចកាន់កាប់ គប់ចោលទាំងស្រុងដោយចេតនា ។ ផ្ទុយទៅវិញ គេបានឃោសនាផ្សាយពាសពេញលើផ្ទៃប្រទេសកម្ពុជា នូវចលនាថ្មី គឺគ្រិស្តសាសនា ។

## ខ– សម័យទី ១ នៃអាណាព្យាបាល (ឆ្នាំ ១៨៦៣ - ១៩៤៥)

អាណាព្យាបាលបារាំងសែស បានតាំងអំណាចខ្លួនលើប្រទេសខ្មែរ តាមសន្ធិសញ្ញា ឆ្នាំ ១៨៦៣ និងអនុសញ្ញា ឆ្នាំ ១៨៨៤ ក្នុងរជ្ជកាលនៃព្រះបាទនរោត្តម ។ ព្រះបាទនរោត្តមទី១ ព្រះអង្គទ្រង់បានជំទាស់យ៉ាងម៉ឺងម៉ាត់ពិសេសចំពោះអនុសញ្ញា ឆ្នាំ១៨៨៤ ដែលបានដកយកអំណាចពីមហាក្សត្រខ្មែរទាំងអស់ ទៅប្រគល់ឲ្យអំណាចអាណាព្យាបាល ។

– តើអនុសញ្ញា ឆ្នាំ ១៨៨៤ ត្រូវបានទទួលឡាយព្រះហស្តលេខារបៀបណា ?

លោក ប៉ូល កូល្លា ដែលបានសរសេរអំពីរឿងនេះ ក្នុងសៀវភៅមួយមានចំណងជើងថា « ប្រទេសខ្មែរទិងប្រជាជនខ្មែរ » បានរៀបរាប់ថា: « នៅថ្ងៃទី១៧ មិថុនា ឆ្នាំ ១៨៨៤ វេលាម៉ោង ២០ កងទ័ពថ្មើរជើងខាងជើងទឹកមួយក្រុម បានចូលទៅក្នុងព្រះបរមរាជវាំង ។ ក្នុងពេលជាមួយគ្នា មានកងកាំភ្លើងធំខាងនាវាមួយក្រុម បានមកចតនៅព្រះបរមរាជវាំងដែរ (ព្រះរាជដំណាក់នៃព្រះមហាក្សត្រ) ។ បន្តិចក្រោយមក លោក ហ្សារលី-ធុមសុន ដោយមានលោក ហ្វូរ៉េស ជាដំណាងអាណាព្យាបាលទៅជាមួយផង បានដើរចូលទៅក្នុងព្រះបរមរាជវាំង ហើយសំដែងនូវបំណងរបស់ខ្លួនថា ចូលព្រះបង្គំគាល់ព្រះមហាក្សត្រ ព្រះបាទនរោត្តមទី ១ ... ។ ព្រះអង្គទ្រង់កំពុងតែផ្ទំនៅឡើយ ។ តាមប្រពៃណីខ្មែរ ដាស់ព្រះមហាក្សត្រដែលកំពុងផ្ទំ ដោយពុំបានទទួលព្រះរាជបង្គាប់ជាមុន គឺទុកដូចជាបទល្មើសមួយយ៉ាងធ្ងន់ ។ ដោយយល់ឃើញនូវស្ថានភាពមិនប្រក្រតី ព្រោះមានក្រុមទាហានមកជាមួយផង មន្ត្រីដែលនៅអមព្រះអង្គក៏បានប្រជុំគ្នា ។ លោក ធុមសុន មិនអាចរង់ចាំយូរបានក្រឡេកមើលនាឡិកាដៃរបស់ខ្លួន ហើយពោលទៅរកលោក ហ្វូរ៉េស និងនាយកខុទ្ទកាល័យរបស់ខ្លួនថា «អស់លោក អ្នកដំណាងប្រទេសបារាំងមិនអាចចាំឲ្យហួសពី១៥នាទីបានឡើយ » ។ ពោលហើយ លោកក៏ដើរចូលទៅក្នុងបន្ទប់ព្រះមហាក្សត្រ ។ ព្រះបាទនរោត្តម ព្រះអង្គទ្រង់កំពុងតែផ្ទំនៅឡើយ ។ តែដោយសូរសព្ទជំហាន ព្រះអង្គទ្រង់តើន ។ គេចាប់អាននូវសេចក្ដីនៃអនុសញ្ញាថ្វាយព្រះអង្គក្នុងពេលនោះភ្លាម ។

កុលឌីម៉ុងតេរ៉ូ ខ្មែរដែលជាប់ពូជពង្សពីជនជាតិ ពរទុគេ ហើយដែលជាអ្នកបកប្រែ និងជាលេខាធិការផ្ទាល់របស់ព្រះមហាក្សត្រ ត្រូវទទួលភារៈបកប្រែនូវអត្ថបទនោះដែលសរសេរជាភាសាបារាំង ។ លុះប្រែចប់ លោកបានក្រាបបង្គំទូលថ្វាយព្រះអង្គថា: "សូមក្រាបបង្គំទូល នេះមិនមែនជាអនុសញ្ញាដែលគេទូលស្នើព្រះអង្គឡើយ ។ នេះគឺជាការបង្ខំឲ្យព្រះអង្គដាក់ពងសម្បត្តិតែម្ដង " ។ លោក កុលឌីម៉ុងតេរ៉ូ ត្រូវគេចាប់ប្រគល់ទៅឲ្យក្រុមទាហាន ដែលមានកាំភ្លើងដោតបំពុះទុងក្នុងតំរង់លោក ។ ប៉ុន្តែការណ៍នេះមិនបានទៅឆ្ងាយទេ ចិត្តបារាំងជាចិត្តអង់អាច. . . ។

ព្រះអង្គទ្រង់ឡាយព្រះហស្តលេខា ។ លោក ធុមសុន ដកខ្លួនថយ ។ ទៅដល់ក្លោងទ្វារ លោកមានប្រសាសន៍ទៅកាន់អ្នកអមលោកថា: "អស់លោក នេះគឺជាទំព័រមួយនៃប្រវត្តិសាស្ត្រ " ។

សេចក្ដីដកស្រង់ខាងលើ ធ្វើឲ្យយើងអាចដឹងថា តើក្នុងកាលៈទេសៈបែបណា បារាំងបានបង្ខំឲ្យព្រះបាទនរោត្តមទី ១ ទ្រង់ឡាយព្រះហស្តលេខាលើអនុសញ្ញា ឆ្នាំ១៨៨៤។

តាមអនុសញ្ញា ឆ្នាំ១៨៨៤ បារាំងបានដកអំណាចទាំងអស់ពីព្រះមហាក្សត្រខ្មែរ ។ តទៅនេះ យើងលើកយកបញ្ហាសំខាន់ៗមកពិនិត្យ គឺ:

១– បញ្ហានយោបាយ: ក្រោមអាណាព្យាបាលបារាំង ប្រទេសកម្ពុជាត្រូវបារាំងត្រួតត្រាទាំងអស់ តាមរយៈភ្នាក់ងាររដ្ឋបាលខ្មែរ ។ ម្ចាស់ទឹកដីនៃប្រទេសខ្មែរ គឺមិនមែនព្រះមហាក្សត្រទេ ។ អំណាចទាំងអស់ ត្រូវបានចូលក្នុងកណ្ដាប់ដៃនៃអ្នកប្រចាំការជាន់ខ្ពស់នៃប្រទេសបារាំងនៅប្រទេសខ្មែរ Résident Supérieur ។ តាមទីរួមខេត្តនានាក្នុងព្រះរាជាណាចក្រ មានបារាំងម្នាក់ជាធំត្រួតត្រាខេត្ត លើអភិបាលខេត្តខ្មែរ ដែលគេហៅថា: "អ្នកប្រចាំការប្រទេសបារាំង Résident de France " ។

ចំណែកកងទ័ពមានពីរក្រុម: មួយក្រុម គេហៅថា "ទ័ពជើងអាណានិគម" ដែលមានសុទ្ធតែបារាំង ។ មួយក្រុមទៀតគឺ កងវរសេនាតូចក្សាឥណ្ឌូចិន ដែលមានបារាំងជាមេ

បញ្ជាការ ។ ចំណែកខាងក្រុមនគរបាល ក៏មានសភាពដូចគ្នាដែរ គឺមាននគរបាលបារាំងសុទ្ធ និងក្រុមនគរបាលជាតិ ដែលស្ថិតនៅក្រោមបញ្ជាការបារាំង ។ អំណាចតុលាការចែកជាតុលាការបារាំង ដែលមានសមត្ថភាពយ៉ាងទូលំទូលាយ និងតុលាការខ្មែរ ដែលមានសមត្ថភាពវិនិច្ឆ័យបានតែរឿងខ្មែរសុទ្ធសាធ ។

ដោយសង្ខេប ប្រទេសខ្មែរបាត់បង់ទាំងអស់ នូវអធិបតីភាពរបស់ខ្លួនខាងនយោបាយ ។

២_ បញ្ហាសេដ្ឋកិច្ច : អំណាចអាណាព្យាបាលពុំបានប្រឹងប្រែង ឬក៏យកចិត្តទុកដាក់ដើម្បីធ្វើឲ្យសេដ្ឋកិច្ចលូតលាស់ឡើយ ក្នុងវិស័យកសិកម្ម ក៏ដូចជាក្នុងវិស័យឧស្សាហកម្មដែរ ។ ក្នុងវិស័យកសិកម្ម លើកលែងតែក្រុមហ៊ុនស្រូវនៅខេត្តបាត់ដំបង ដែលគេបានប្រើប្រាស់ដី និងគ្រឿងម៉ាស៊ីនបន្តិចបន្តួច ហើយនិងចំការកៅស៊ូដែលជាកម្មសិទ្ធិរបស់បារាំង ស្ថានភាពទូទៅនៃកសិកម្មពុំមានការប្រែប្រួល ផ្លាស់ប្តូរអ្វីបន្តិចឡើយ ។ មិនតែប៉ុណ្ណោះ អំណាចព្យាបាលបានទាំងហាមឃាត់មិនឲ្យប្រជាកសិករខ្មែរដាំដុះ នូវដំណាំខ្លះផងទៀត ដូចជា កប្បាសជាដើម ។ ក្នុងវិស័យឧស្សាហកម្មក៏ដូច្នេះដែរ ។ ប្រទេសខ្មែរក្នុងសម័យនោះ គ្មានឧស្សាហកម្មអ្វីជាដុំដុំសំខាន់ឡើយ ក្រៅពីម៉ាស៊ីនកិនស្រូវ រោងអារឈើ កន្លែងបិតស្រា និងកន្លែងធ្វើទឹកកក បន្តិចបន្តួចប៉ុណ្ណោះ ។ ឯពាណិជ្ជកម្មក្រៅប្រទេស គឺស្ថិតនៅក្រោមអំណាចបារាំងទាំងអស់ ។

៣_ បញ្ហាវប្បធម៌និងសង្គមកិច្ច : ក្នុងសម័យអាណាព្យាបាល បារាំងពុំបានធ្វើអ្វីជាសំខាន់ ដើម្បីថែរក្សាលើកតម្កើងវប្បធម៌ជាតិឡើយ ។ កុលបុត្រ កុលធីតាខ្មែរ បានត្រូវបង្ខំឲ្យសិក្សាភាសាបារាំងពីបឋមវ័យ ( តាំងពីថ្នាក់កុមារដ្ឋាន ) ។ បើនិយាយរួម តាំងពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៤៥ ក្នុងប្រទេសកម្ពុជាទាំងមូល មានអនុវិទ្យាល័យមួយ

វិទ្យាល័យមួយ និង សាលាបឋមសិក្សាបួន-ដប់ប៉ុណ្ណោះ ។ អនក្ខរភាពនៃប្រជាពលរដ្ឋខ្មែរមានចំនួនប្រមាណដល់ទៅ ៩០% ។ នយោបាយបិទការសិក្សា កុំឲ្យជ្រួតជ្រាបទៅក្នុងប្រជារាស្ត្រ និងបំបាត់នូវភស្តុតាងនៃវប្បធម៌ជាតិ ជាគោលដៅនៃអំណាចអាណាព្យាបាលបារាំងក្នុងសម័យនោះ ។

ក្នុងវិស័យសង្គមកិច្ចវិញ ស្ថានភាពក៏ពុំបានល្អដែរ ។ ក្នុងសម័យអាណាព្យាបាលលើកទី ១ ( ១៨៦៣-១៩៤៥ ) គេសង្កេតឃើញមានតែមន្ទីរពេទ្យមួយនៅភ្នំពេញ និងគិលានដ្ឋានបួន-ដប់ នៅតាមទីរួមខេត្ត ។ បុគ្គលិកគ្រូពេទ្យមានប្រមាណ ១០ នាក់ប៉ុណ្ណោះ បើគេរាប់ទាំងគ្រូពេទ្យខ្មែរ បារាំង វៀតណាមបូកគ្នាទាំងអស់ ។ ក្រសួងអនាម័យមួយបានត្រូវបង្កើតនៅរាជធានី តែក្រសួងនោះមានតែឈ្មោះ ។

ចាប់ពីឆ្នាំ ១៩៤១ ដល់ឆ្នាំ ១៩៤៥ ប្រទេសខ្មែរត្រូវស្ថិតនៅក្រោមអំណាចបារាំងផងអំណាចជប៉ុនផង ។ ដូច្នេះ ស្ថានភាពខាងផ្ទៃក្នុងប្រទេស រឹតតែយ៉ាប់យ៉ឺនខ្លាំងឡើងៗ ពីព្រោះកាលនោះ គឺជាពេលដែលមហាសង្គ្រាម ឆ្នាំ ១៩៣៩ - ១៩៤៥ កំពុងរាតត្បាតពាសពេញលើសកលលោក ។

## គ– សម័យទី ២ នៃអាណាព្យាបាល ( ១៩៤៥ - ១៩៥៣ )

លុះសង្គ្រាមសកលលោកលើកទី ២ បានផុតរលត់ទៅ បារាំងបានវិលត្រឡប់មកវិញដើម្បីត្រួតត្រាប្រទេសខ្មែរតទៅទៀត ថ្វីបើអំណាចរបស់ខ្លួនត្រូវផុតរលត់ សាបសូន្យក្នុងពេលដែលកងទ័ពជប៉ុនដណ្តើមយកបាន នៅខែ មិថុនា ១៩៤៥ ក៏ដោយ ។ ប៉ុន្តែឈមមុខនិងស្ថានភាពថ្មី ឈមមុខនិងចលនាសេរីការជាតិ ដែលលូតលាស់រីកពាសពេញអាស៊ី-អាហ្វ្រិក និង អាមេរិកឡាទីន ប្រទេសបារាំងបានប្រកាន់យកនូវអាកប្បកិរិយាទន់ភ្លន់ជាងសម័យមុន ។

ក្នុងវិស័យនយោបាយ បារាំងនៅតែបន្តការត្រួតត្រារបស់ខ្លួនដដែល គ្រាន់តែមានប្រែប្រួលរូបភាពខាងក្រៅបន្តិចបន្តួចប៉ុណ្ណោះ ដូចជា " អ្នកប្រចាំការជាន់ខ្ពស់ Résident

Supérieur" ប្រែទៅជា "ស្នងការជាន់ខ្ពស់ Haut commissaire" ហើយនិង "អ្នកប្រចាំការប្រទេសបារាំង Résident de France" ដែលមានគ្រប់ខេត្ត ដើម្បីត្រួតត្រាលើអភិបាលខេត្តទាំងឡាយនោះ ប្រែទៅជា "ទីប្រឹក្សា Conseillers" ទៅវិញ ។ ក្នុងសម័យទី២នៃអាណាព្យាបាល គេបានបង្កើតកងទ័ពជាតិ ដែលមានព្រះមហាក្សត្រ ទ្រង់ជាព្រះអគ្គបញ្ជាការជាន់ខ្ពស់ ។ គេបានបង្កើតនូវសាលាយោធភូមិន្ទ ដើម្បីហ្វឹកហ្វឺនដល់នាយទាហានខ្មែរ ។ ក្នុងវិស័យតុលាការ បារាំងអនុញ្ញាតបន្ថែមអំណាចឲ្យខ្មែរខ្លះទៀត ចាប់តាំងពីឆ្នាំ១៩៤៩ មក ។ គេសង្កេតឃើញមានការចំរើនខ្លះៗដែរ ក្នុងវិស័យសេដ្ឋកិច្ច (ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម) ក្នុងវិស័យវប្បធម៌ និងសង្គមកិច្ច (មានការកើនចំនួនសាលាបឋមសិក្សា និងមធ្យមសិក្សា គិលានដ្ឋាន និងមន្ទីរចែកឧសថ -គេបានបង្កើតក្រសួងអប់រំមូលដ្ឋានជាតិ -ល-) ។ ប៉ុន្តែការប្រែប្រួល ការផ្លាស់ប្តូរសំបកក្រៅទាំងនោះ ពុំបានធ្វើឲ្យធម្មជាតិនៃការត្រួតត្រាលើប្រទេសខ្មែរផ្លាស់ប្តូរផងដែរទេ ។

ក្នុងឆ្នាំ១៩៤៩ ប្រទេសបារាំងសុខចិត្តព្រមទទួលចុះហត្ថលេខាលើសន្ធិសញ្ញាមួយ ដែលទទួលស្គាល់នូវឯករាជ្យខ្មែរតាមផ្លូវច្បាប់ តែការពិតវិញ ប្រទេសខ្មែរនៅជាប់និងប្រទេសបារាំងដដែល ដោយបារាំងពុំព្រមប្រគល់ឲ្យប្រទេសខ្មែរ នូវអំណាចកងទ័ព-ខាងតុលាការ - ខាងគយនិងខាងកិច្ចការបរទេសឡើយ -ល- ។

★

## II. ការវិវត្តន៍នៃប្រទេសខ្មែរទៅរកឯករាជ្យជាតិ

សេចក្តីផ្តើម : ក្រោយសង្គ្រាមលោកលើកទី ២ ប្រជាពលរដ្ឋដែលនៅក្រោមនឹមអាណានិគមនិយម ក្នុងភូមិភាគអាស៊ី - អាហ្វ្រិក ហើយដែលបានជួយចៅហ្វាយនាយរបស់ខ្លួន ដើម្បីធ្វើចម្បាំងប្រយុទ្ធតទល់នឹងប្រទេសអាល្លឺម៉ង់ ប្រទេសអ៊ីតាលី ប្រទេសជប៉ុន មានចិត្តសង្ឃឹមថា មុខតែចៅហ្វាយនាយប្រគល់ដល់ខ្លួនវិញនូវសេរីភាព នូវឯករាជ្យភាព

កាលណាសង្គ្រាមបានផុតរលត់ទៅ ។ ប៉ុន្តែផ្ទុយនឹងការសង្ឃឹមទុកជាមុននេះ មហាអំណាចអាណានិគមទាំងឡាយ បានវិលត្រឡប់ចូលមកជិះជាន់អតីតអាណានិគមរបស់គេតទៅទៀត ។ ការវិលត្រឡប់នៃមហាអំណាចអាណានិគមខាងលើ បានបង្កើតនូវការមិនសប្បាយចិត្ត នៃប្រជាពលរដ្ឋដែលធ្លាប់ត្រូវគេជិះជាន់ ដែលជាហេតុញុំាងឲ្យប្រជាជនទាំងនេះ កាន់អាវុធប្រឆាំងតបទៅវិញយ៉ាងម៉ឺងម៉ាត់ ដើម្បីរំដោះជាតិមាតុប្រទេសរបស់គេពីនឹមអាណានិគម ។ ដោយការតស៊ូឥតចុះញ៉ម ប្រទេសទាំងឡាយនៅក្នុងភូមិភាគអាស៊ីបានបំរះខ្លួនផុតពីក្រញាំអាណានិគម ដូចជាប្រទេសឥណ្ឌា នឹងប្រទេសភូមា (១៩៤៧) ប្រទេសចិន និង ឥណ្ឌូណេស៊ី (១៩៤៩) ទ្វីបឥណ្ឌូចិន (១៩៥៣–១៩៥៥)-ល- ។

## លំដាប់សំខាន់ ៗ នៃការវិវត្តន៍របស់ប្រទេសកម្ពុជាទៅរកឯករាជ្យ

ចាប់ពីពេលចប់សង្គ្រាមមក ប្រទេសខ្មែរបានឆ្លងកាត់នូវលំដាប់ជាសំខាន់ ៗ បី ក្នុងការវិវត្តន៍របស់ខ្លួន ទៅរកឯករាជ្យ :

### ១– សន្ធិសញ្ញាបណ្តោះអាសន្ន ឆ្នាំ១៩៤៦

កិច្ចសំរុះសំរួលនេះ ជាសន្ធិសញ្ញាបណ្តោះអាសន្នមួយ ដែលត្រូវបានស្ថាបនាឡើង ដើម្បីជំនួសអនុសញ្ញា “ convention ” ឆ្នាំ ១៨៨៤ ពីព្រោះអនុសញ្ញានេះ បានបាត់តំលៃរបស់ខ្លួនអស់ ក្រោយពីកងទ័ពហ្វាស៊ីសជប៉ុនដណ្តើមយកអំណាចបានពីបារាំងក្នុងឆ្នាំ ១៩៤៥ ។ តាមរយៈកិច្ចសំរុះសំរួលខាងលើ បារាំងក៏បានចូលមកត្រួតត្រាប្រទេសខ្មែរដូចដើម ។ មុននឹងចុះហត្ថលេខាលើកិច្ចសំរុះសំរួលខាងលើ បារាំងបានសន្យាថា នឹងសុខចិត្តព្រមចុះហត្ថលេខាលើសន្ធិសញ្ញាជាស្ថាពរមួយក្នុងពេលខាងមុខដ៏ឆាប់ ៗ តែផ្ទុយទៅវិញ បារាំងពន្យាពេលរហូតដល់ឆ្នាំ ១៩៤៩ ទើបព្រមចុះហត្ថលេខាលើសន្ធិសញ្ញាខាងលើ ។

## ២- សន្ធិសញ្ញាបារាំង-ខ្មែរ ឆ្នាំ១៩៤៩

សន្ធិសញ្ញាបារាំង-ខ្មែរ ដែលជំនួសសន្ធិសញ្ញាបណ្ដោះអាសន្នឆ្នាំ ១៩៤៦ ត្រូវបានចុះហត្ថលេខា នៅថ្ងៃទី ៨ វិច្ឆិកា ឆ្នាំ១៩៤៩ រវាងព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះមហាក្សត្រខ្មែរ គឺអ្នកអង្គម្ចាស់ស៊ីសុវត្ថិមុនីពង្ស និង លោកប្រធានាធិបតីនៃសាធារណរដ្ឋបារាំង វ៉ាំងសង់ អូរីយ៉ូល ។ សន្ធិសញ្ញាបារាំង-ខ្មែរខាងលើ ពុំបានដោះស្រាយនូវបញ្ហាសំខាន់ៗរបស់ខ្មែរឡើយ ពោលគឺពុំបានផ្ដល់ដល់ប្រទេសខ្មែរនូវឯករាជ្យពេញលេញឡើយ ។ អាស្រ័យហេតុនេះ រដ្ឋសភាខ្មែរពុំព្រមអនុម័តឲ្យសច្ចាប័នលើសន្ធិសញ្ញាខាងលើ ហើយបានទាត់ចោលជាពីរលើកផងទៀត ។ តាមសៀវភៅ “គ្រាំងលឿង” សន្ធិសញ្ញាឆ្នាំ ១៩៤៩ បានធ្វើឲ្យ “ខកចិត្ត” ជាច្រើន ពីព្រោះសន្ធិសញ្ញានេះ បានបង្ខំឲ្យប្រទេសខ្មែរ ស្ថិតនៅក្នុងសហធិបតីភាពជាមួយនឹងប្រទេសបារាំង ។

## ៣- រាជបូជនីយកិច្ច ដើម្បីទាមទារឯករាជ្យ ឆ្នាំ១៩៥២-៥៣

សន្ធិសញ្ញាបារាំង-ខ្មែរឆ្នាំ១៩៤៩ ពុំបានផ្ដល់ឯករាជ្យដល់ប្រទេសខ្មែរឡើយ ហើយបានធ្វើឲ្យខ្មែរបាក់បែកគ្នាជាច្រើន ។ ហេតុដូច្នេះហើយ ទើបព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុវរ្ម័ន ព្រះអង្គទ្រង់ធ្វើព្រះរាជបូជនីយកិច្ច ដើម្បីទាមទារឯករាជ្យជូនជាតិមាតុប្រទេស ។ រាជបូជនីយកិច្ចបានចាប់ផ្ដើមធ្វើពីខែ កុម្ភៈ ដល់ខែ វិច្ឆិកា ឆ្នាំ ១៩៥៣ ។

### ក-ព្រះរាជដំណើរនៃព្រះមហាក្សត្រទៅកាន់ប្រទេសបារាំងថ្ងៃទី៩វិច្ឆិកា១៩៥៣

ព្រះមហាក្សត្រនិងសហការីរបស់ព្រះអង្គ ទ្រង់ស្ដេចយាងនិងអញ្ជើញទៅកាន់ប្រទេសបារាំង ហើយព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទ្រង់គង់នៅទីក្រុង ណាពូល ដែលជាទីក្រុងមួយតូចនៅក្នុងភូមិភាគមួយហៅថា «អាល់ម៉ារីទីប» ។ នៅទីនោះ ព្រះអង្គបានផ្ញើចុតហ្មាយមួយទៅលោកប្រធានាធិបតីនៃសាធារណរដ្ឋបារាំង តែរដ្ឋាភិបាលបារាំងពុំបានឆ្លើយតបនឹងលិខិតរបស់ព្រះអង្គឡើយ ។

ក្នុងពេលជាមួយគ្នានោះ នៅទីក្រុងប៉ារីស រដ្ឋាភិបាលបារាំងនិងរាជរដ្ឋាភិបាលខ្មែរ ក៏បានធ្វើការចរចាអំពីបញ្ហានេះដែរ ។

## ខ– ព្រះរាជដំណើរនៃព្រះមហាក្សត្រឆ្ពោះទៅអាមេរិកខាងជើង

ដោយការឆ្លើយរបស់រដ្ឋាភិបាលបារាំងមានលក្ខណៈគេចវេះ ពន្យាពេលជានិច្ចនិរន្តរ៍ ព្រះមហាក្សត្រខ្មែរទ្រង់ស្ដេចយាងចាកចេញពីប្រទេសបារាំង ឆ្ពោះទៅសហរដ្ឋអាមេរិក ។ នៅទីនោះព្រះអង្គទ្រង់បង្ហើបមតិអន្តរជាតិតាមសារពត៌មានធំៗ ។ តែរដ្ឋាភិបាលកាណាដាក្តី រដ្ឋាភិបាលសហរដ្ឋអាមេរិកក្តី ដោយខ្លាចបារាំងខឹង ពុំបានគាំទ្រនូវគោលបំណងរបស់ខ្មែរឡើយ ។ ផ្ទុយទៅវិញ គេបែរជាប្រដៅខ្មែរកុំឲ្យទាមទារឯករាជ្យពីបារាំងទៅវិញ ។

## គ– ព្រះមហាក្សត្រខ្មែរនៅតូក្យូ – ដើមខែ ឧសភា ១៩៥៣

នៅពេលដែលព្រះអង្គទ្រង់ព្រះរាជនិវត្តមកកាន់ប្រទេសខ្មែរវិញ ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហឫទ័យស្នាក់អាស្រ័យនៅទីក្រុងតូក្យូ ដើម្បីរង់ចាំទទួលនូវលទ្ធផលនៃការពិភាក្សានៅក្រុងប៉ារីស រវាងរដ្ឋាភិបាលបារាំង និងរាជរដ្ឋាភិបាលខ្មែរ ។ ដោយការចរចាខាងលើពុំបានសម្រេចលទ្ធផលអ្វី ព្រះអង្គទ្រង់ធ្វើសន្និសីទកាសែតនៅទីនោះ ដើម្បីលាតត្រដាងបង្ហាញដល់មតិអន្តរជាតិ នូវសេចក្ដីប្រាថ្នារបស់ប្រជាជនខ្មែរ ។

## ឃ– ព្រះរាជនិវត្តន៍នៃព្រះមហាក្សត្រមកក្រុងភ្នំពេញ – ១៤.៥.១៩៥៣

ព្រះមហាក្សត្រទ្រង់ព្រះរាជនិវត្តមកដល់ក្រុងភ្នំពេញវិញ នៅថ្ងៃទី ១៤ ឧសភា ១៩៥៣ ដើម្បីទ្រង់បន្តព្រះសកម្មភាពតទៅទៀត ។ ប៉ុន្តែពេលនោះ បារាំងបានដឹកទ័ពរបស់គេមកជាច្រើន ព្រមទាំងបានភ្ជង់កាំភ្លើងធំតម្រង់ចំទៅព្រះបរមរាជវាំងទៀតផង ។ ស្ថានភាពដ៏លំបាកនេះ មិនអាចឲ្យព្រះមហាក្សត្រទ្រង់បំពេញព្រះសកម្មភាពដោយប្រសិទ្ធភាពបានឡើយ ។

## ង– ព្រះរាជដំណើរទៅកាន់ក្រុងបាងកក – ១៣ . ៦ . ១៩៥៣

អាស្រ័យហេតុនេះ ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យទ្រង់ភៀសព្រះអង្គដោយចេតនាទៅគង់នៅទីក្រុងបាងកក ដោយព្រះអង្គទ្រង់យល់ថា ជាឋានមួយធំនៅតំបន់អាស៊ីអាគ្នេយ៍ ហើយជិតប្រទេសខ្មែរទៀតផង ។ ស្ថានភាពជាអនុគ្រោះនោះ អាចឲ្យព្រះមហាក្សត្រ បន្តព្រះរាជសកម្មភាពរបស់ព្រះអង្គ ដើម្បីទាមទារឯករាជ្យ ។ ប៉ុន្តែរាជរដ្ឋាភិបាលថៃ ដោយខ្លាចចិត្តបារាំងនឹងប័ក្សសម្ពន្ធខាងបស្ចិមប្រទេសរបស់គេ ពុំអនុញ្ញាតឲ្យព្រះមហាក្សត្រទទួលនូវលក្ខន្តិកៈជា " ជនភៀសខ្លួនខាងនយោបាយ " ឡើយ ដែលជាឧបសគ្គដល់ព្រះរាជសកម្មភាពរបស់ព្រះមហាក្សត្រ ។

## ច– ព្រះរាជនិវត្តន៍នៃព្រះមហាក្សត្រមកតំបន់ស្វយ័ត – ២០ . ៦ . ១៩៥៣

គ្មានសេចក្ដីសង្ឃឹមនឹងបន្តព្រះរាជសកម្មភាពនៅទីក្រុងបាងកកបាន ព្រះមហាក្សត្រទ្រង់យាងនិវត្តមកកាន់តំបន់ស្វយ័ត ក្នុងខេត្តបាត់ដំបង - សៀមរាប - កំពង់ធំ ។ នៅទីនោះព្រះអង្គទ្រង់បានបង្កើតកងជីវពល - នារីក្លាហាន ។

## ឆ– លទ្ធផលនៃកិច្ចចរចាបារាំង – ខ្មែរ នៅបារីស

ព្រះរាជសកម្មភាពនៅក្នុងប្រទេសខ្មែរក្ដី នៅបរទេសក្ដី បានជួយជាច្រើនដល់កិច្ចចរចាបារាំង - ខ្មែរ នៅក្រុងបារីស ដែលបានសម្រេចដូចបំណងនៃប្រជាពលរដ្ឋខ្មែរ ។ នៅថ្ងៃទី ៩ វិច្ឆិកា ឆ្នាំ១៩៥៣ សាធារណរដ្ឋបារាំង បានសុខចិត្តប្រគល់ជាផ្លូវការ ដល់រាជរដ្ឋាភិបាលខ្មែរ នូវបញ្ហាការកងទ័ព ។ កាលបរិច្ឆេទប្រកបដោយនក្ខត្តឫក្សនេះ ជាកាលបរិច្ឆេទជាប្រវត្តិសាស្ត្រ នៃឯករាជ្យជាតិប្រទេសខ្មែរ ។

រាជបូជនីយកិច្ចដើម្បីទាមទារឯករាជ្យជាតិក៏បានចប់ត្រឹមនេះ ។ ការចាប់ផ្ដើមនៃសម័យថ្មីមួយទៀត ក៏បានត្រូវប្រព្រឹត្តតាំងពីពេលនោះមក ពោលគឺជាសម័យនៃប្រវត្តិសាស្ត្រនយោបាយនៃប្រទេសខ្មែរឯករាជនិងអធិបតី ។

## III. ប្រទេសកម្ពុជាក្រោយឯករាជ្យ

ប្រវត្តិសាស្ត្រនយោបាយនៃប្រទេសកម្ពុជា ចាប់តាំងពីបានឯករាជ្យ នឹងអធិបតីភាពមក បានជិតជាប់តែនឹងនាមមួយប៉ុណ្ណោះ គឺសម្តេចព្រះនរោត្តម សីហនុ ។ កន្លងអតីតកាលមិនយូរប៉ុន្មាន ព្រះបាទនរោត្តម សីហនុ ទ្រង់ជាព្រះមហាក្សត្រគ្រប់គ្រងរាជសម្បត្តិ តាមគន្លងប្រពៃណីយ៉ាងតឹងរឹង សុទ្ធសាធនៃព្រះមហាក្សត្រនាសម័យអង្គរ ។ សព្វថ្ងៃ ព្រះអង្គទ្រង់ជាព្រះប្រមុខរដ្ឋមួយអង្គ ប្រកបដោយប្រជាប្រិយភាពជាទីបំផុត ហើយទ្រង់មានគំនិតទូលំទូលាយស្រឡាញ់សេរីភាព ប្រជាធិបតេយ្យ ។ គេអាចសន្និដ្ឋានបានថា ព្រះបាទនរោត្តម សីហនុ ជានិមិត្តរូបពិតប្រាកដនៃប្រទេសកម្ពុជាទំនើប នឹងបច្ចុប្បន្ន ។

## សមិទ្ធិនៃសង្គមរាស្ត្រនិយម

សេចក្តីផ្តើម : ចាប់តាំងពីព្រះអង្គទ្រង់ដាក់រាជសម្បត្តិ ថ្វាយទៅព្រះរាជបិតាព្រះអង្គ ព្រះបាទនរោត្តមសុរាម្រឹត ហើយក្រោយពីបានរៀបចំធ្វើប្រជាមតិមួយ ដែលបានអនុម័តជិតមួយរយភាគរយ (១០០ %) លើគ្រប់ព្រះរាជសកម្មភាពទាំងឡាយ ពិសេសចំពោះព្រះរាជបូជនីយកិច្ចដើម្បីទាមទារឯករាជ្យ ព្រះបាទនរោត្តម សីហនុ ទ្រង់បានស្ថាបនានូវមូលដ្ឋានមួយយ៉ាងរឹងប៉ឹង ដែលជាការធានាអះអាងដល់ការកសាងប្រទេសខ្មែរទៅអនាគត ។

ចលនាសង្គមរាស្ត្រនិយម ដែលជាអង្គការប្រមែប្រមូលនូវប្រជាជនខ្មែរគ្រប់ស្រទាប់ថ្នាក់ឥតរើសអើងពណ៌សំបុរនយោបាយ ហើយដែលបានបង្កើតឡើង នឹងដឹកនាំដោយព្រះអង្គផ្ទាល់នោះ បានបំពេញការៈមួយយ៉ាងសំខាន់ក្នុងការស្ថាបនាជាតិ ។

ផ្លូវដែលប្រទេសជាតិបានដើររួចមកហើយ ប្រមាណ ១០ ឆ្នាំបាយប៉ុណ្ណោះ មិនជាវែងឆ្ងាយប៉ុន្មានទេ ប្រសិនបើប្រៀបធៀបទៅនឹងរយៈវេលាខាងប្រវត្តិសាស្ត្រ ប៉ុន្តែស្នាដៃដែលបានសម្រេចមានចំនួនច្រើនហួសពីការស្មានទុក ហើយការលូតលាស់រីកចំរើននេះទៀតសោត គឺមានគ្រប់វិស័យនៃជីវភាពជាតិទាំងមូល ។

ក- ក្នុងវិស័យនយោបាយ : ក្នុងវិស័យនយោបាយ ប្រទេសខ្មែរបានបញ្ចប់ការវិវត្តន៍ទៅរកប្រជាធិបតេយ្យភាពរបស់ខ្លួនដោយការ :

– បើកសិទ្ធិបោះឆ្នោតដល់ស្ត្រីភេទ

– កែប្រែរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ បង្កើតឲ្យមានសភាក្រុង និងសភាខេត្ត

– បង្កើតសមាជជាតិ ។ សមាជជាតិបើកសម័យប្រជុំ ៦ ខែម្តង ហើយក្នុងពេលសមាជម្តង ៗ ប្រជាពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ អាចឡើងទៅបញ្ចេញយោបល់របស់ខ្លួនចំពោះបញ្ហាសំខាន់ៗទាំងឡាយ ដែលទាក់ទងនឹងជីវភាពជាតិទាំងមូល ។

ការបង្កើតចលនាយុវជនសង្គមនិយមខ្មែរ ដែលសម្តេចព្រះឧបយុវរាជទ្រង់ជាអ្នកផ្តើមគំនិតផង ជាប្រធានផង គឺជាជំហានមួយដ៏មានអត្ថន័យយ៉ាងសំខាន់ ក្នុងការប្រមូលផ្តុំនូវគ្រប់ជីវពលជាតិ ដើម្បីស្ថាបនាកសាងប្រទេសឡើងវិញ ទៅតាមមូលភាពសង្គមនិយមជាតិមានពុទ្ធនិយមជាមូលដ្ឋាន ។

ជាចុងក្រោយបំផុត ព្រឹត្តិការណ៍នយោបាយដ៏សំខាន់មួយទៀត គឺការប្រគល់មកឲ្យប្រទេសកម្ពុជាវិញ ដោយតុលាការអន្តរជាតិ នូវប្រាសាទព្រះវិហារ ដែលប្រទេសថៃបានដណ្តើមយកបន្ទាប់ពីពេលដែលខ្មែរបានទទួលឯករាជ្យពេញលេញមក ។

ក្នុងឆាកអន្តរជាតិ ប្រទេសខ្មែរបានប្រកាន់យ៉ាងខ្ជាប់ខ្ជួន នូវនយោបាយអព្យាក្រឹត ពុំចូលខាងបុកណាឡើយ ហើយនយោបាយនេះ គឺផ្អែកទៅលើមូលភាព ៥ ខ នៃការរួមរស់ដោយសន្តិភាព ( សីលប្រាំ ) និងមូលភាព ១០ ខ ដែលសន្និសីទអាស៊ី - អាហ្វ្រិក ( ឆ្នាំ ១៩៥៥ ) នៅទីក្រុងបាន់ឌុង Bandung បានប្រកាសទុកជាមាគ៌ានយោបាយក្នុងការទាក់ទងអន្តរជាតិ ហើយដែលប្រទេសកម្ពុជា បានចូលរួមយ៉ាងសកម្មក្នុងសន្និសីទនោះដែរ ។

នយោបាយអព្យាក្រឹត ដែលប្រទេសកម្ពុជាបានប្រកាន់យ៉ាងខ្ជាប់ខ្ជួននេះ បានធ្វើឲ្យខ្លួនបំពេញនូវមុខងារមួយយ៉ាងសំខាន់ក្នុងឆាកអន្តរជាតិ ហើយនិងថែរក្សាបានខាងផ្ទៃ

ក្នុងប្រទេស នូវឯកភាព សន្តិភាព ក្នុងដំបន់មួយដែលពោរពេញទៅដោយការគេរករល្អក់ បណ្ដាលមកពីសង្គ្រាម ។

២_ ក្នុងវិស័យសេដ្ឋកិច្ច : ក្រោយពីបានឯករាជ្យ គេសង្កេតឃើញមានការប្រែប្រួលផ្លាស់ប្ដូរជាច្រើនក្នុងវិស័យសេដ្ឋកិច្ច ។ ជាបឋម ប្រទេសកម្ពុជាបានបង្កើតធនាគារជាតិ ដើម្បីទទួលភារៈបោះក្រដាសប្រាក់រៀល (ជំនួសរូបិយវត្ថុ ឥណ្ឌូចិន) ព្រមទាំងបានបង្កើតជាតិមន្ទីរប្ដូរប្រាក់ ដែលទទួលភារៈត្រួតត្រាលើគ្រប់សកម្មភាពខាងរូបិយវត្ថុរបស់ប្រទេស ។

ផែនការពីរឆ្នាំ ( ១៩៥៧ - ១៩៥៨ ) បានត្រូវស្ថាបនាជាដំបូង ដើម្បីផ្ដល់ដល់ប្រទេស នូវគ្រឿងបរិក្ខារសង្គ្រោះ: គោលគឺដើម្បីជួសជុលឡើងវិញនូវថ្នល់ - ស្ពាន - ល - ទាំងឡាយដែលត្រូវខូចខាតក្នុងពេលអសន្តិសុខ ។ លទ្ធផលនៃការអនុវត្តន៍នូវផែនការខាងលើ ត្រូវបានសម្រេចគួរជាទីពេញចិត្ត ។ ដោយផ្អែកលើមូលដ្ឋាននៃផែនការ២ឆ្នាំ គេអាចស្ថាបនាផែនការដទៃទៀត ដូចជាផែនការ ៥ ឆ្នាំ ( ១៩៦០ - ១៩៦៤ ) ជាដើម ។ ផែនការខាងក្រោយ មានគោលដៅពង្រីកផលិតកម្ម ខាងកសិកម្មនិងខាងឧស្សាហកម្ម ។ ដោយសង្ខេប ផែនការប្រាំឆ្នាំ ដែលបានចាប់អនុវត្តតាំងពីឆ្នាំ ១៩៦០ បានគ្រោងទុកនូវការបង្កើនកម្រៃធនធានប្រជារាស្ត្រឲ្យបានយ៉ាងតិចត្រឹម ៣,៣% ក្នុងឆ្នាំ ១៩៦៤ ។ ដើម្បីអនុវត្តឲ្យបានជោគជ័យនូវផែនការខាងលើ សម្ដេចព្រះប្រមុខរដ្ឋ ទ្រង់បានបញ្ចូលនយោបាយទឹក និងការហត្ថកម្ម ។ ម្យ៉ាងទៀត រាជរដ្ឋាភិបាលបានបង្កើត “មន្ទីររាជសហករណ៍„ ដើម្បីជួយដល់រាស្ត្រក្រីក្រតូចតាច ឲ្យគេចផុតពី “ឈ្មួញកណ្ដាល„ និងជួយឥណទានដល់សមាជិកនៃសហករណ៍ ដើម្បីយកទៅប្រើប្រាស់ពង្រីកផលិតផលកសិកម្មរបស់ខ្លួន ។

ជាចុងក្រោយបំផុត វិធានការដ៏មានសារៈសំខាន់ក្នុងវិស័យសេដ្ឋកិច្ច គឺការកែទម្រង់សេដ្ឋកិច្ចដែលសម្ដេចព្រះប្រមុខរដ្ឋ ទ្រង់បានអនុវត្តនៅខែ វិច្ឆិកា ឆ្នាំ១៩៦៣ ។ ការកែទម្រង់សំខាន់ៗមាន :

- ជាគូបនីយកម្មនៃមុខរបរនាំចេញ - នាំចូល
- ជាគូបនីយកម្មនៃមុខរបរខាងធនាគារ
- ជាគូបនីយកម្មនៃមុខរបរខាងធានារ៉ាប់រង
- ការបង្កើតនូវផ្នែកសេដ្ឋកិច្ចមួយ ដែលរដ្ឋទទួលកាន់កាប់ទាំងស្រុង ។ល។

វិធានការទាំងនេះ ដែលមានប្រយោជន៍ដល់អាយុជីវិតនៃប្រទេស ត្រូវបានអនុវត្តក្រោយពីការផាត់ចោលយ៉ាងទទ្បារិក នូវជំនួយអាមេរិកាំងគ្រប់បែបយ៉ាង ។ ការកែទម្រង់សេដ្ឋកិច្ចខាងលើ មានគោលដៅឆ្ពោះទៅរកឯករាជ្យខាងសេដ្ឋកិច្ច ដែលជាមូលដ្ឋាននៃឯករាជ្យនយោបាយ ។

៣- វិស័យសង្គមកិច្ច - វប្បធម៌ៈ តាំងពីបានឯករាជ្យ ការចំរើនមានច្រើនក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌ ។ ក្រសួងសុខាភិបាលសាធារណៈ បានត្រូវរៀបចំជាថ្មី ។ មន្ទីរពេទ្យ គិលានដ្ឋាន មន្ទីរចែកឱសថ មជ្ឈមណ្ឌលសុខភាព ជាច្រើនបានត្រូវស្ថាបនានៅតាមទីក្រុង និងតាមជនបទ ។ ចំនួនគ្រែសម្រាប់អ្នកជម្ងឺបានកើនយ៉ាងច្រើន ឯចំនួនវេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុដ្ឋាក ឆ្មប ក៏បានកើនយ៉ាងធាប់រហ័សដែរ ។

លំនៅឋាននៅតាមទីក្រុងក្តី នៅតាមជនបទក្តី ក៏មានសភាពស្អាតស្អំសមរម្យ ។ ឯរាជធានី និងទីរួមខេត្ត ទីប្រជុំជន ក៏បានផ្លាស់ប្តូរប្រែប្រួលរូបភាពយ៉ាងច្រើន ។

ក្នុងពេលថ្មីៗនេះទៀត រដ្ឋាភិបាលបានបញ្ញត្តច្បាប់ការងារ ដើម្បីការពារផលប្រយោជន៍កម្មករ ដូចជាតម្រូវឲ្យម្ចាស់សហគ្រាសផ្តល់ដល់នយោជិតរបស់ខ្លួន នូវអត្ថប្រយោជន៍ផ្សេងៗខាងសង្គម ដែលត្រូវបានទទួលស្គាល់ជាយូរអង្វែងណាស់មកហើយនៅក្នុងប្រទេសដែលមានឧស្សាហកម្មលូតលាស់ ដូចជា ឈប់សំរាកមានបៀវត្ស - ប្រាក់បំណាច់ចំពោះគ្រោះថ្នាក់ក្នុងពេលបំពេញការងារ - កម្រៃសម្រាប់គ្រួសារ. . . ។

ក្នុងវិស័យវប្បធម៌ ការរីកចំរើនមានល្បឿនឆាប់រហ័សក្រៃលែង ពិសេស គឺសិក្សាធិការជាតិគ្រប់ភូមិទាំងអស់ (បឋមភូមិ-មធ្យមភូមិ-ឧត្តមភូមិ) ។ សព្វថ្ងៃប្រទេសខ្មែរមានសកលវិទ្យាល័យចំនួន ៧ និងមហាវិទ្យាល័យប្រមាណ ៤០ ដែលចែកចាយដល់កុលបុត្រកុលធីតានូវគ្រប់វិជ្ជាទាំងអស់ ។ ចំនួនបុគ្គលិកសិក្សាក្ដី ចំនួនសិស្សក្ដី ចំនួនអគារសិក្សាក្ដី បានរីកចំរើនកើនយ៉ាងឆាប់ក្នុងរយៈកាលមួយដ៏ខ្លី ។

ម្យ៉ាងទៀត ដោយសារនយោបាយអព្យាក្រឹត ប្រទេសកម្ពុជាអាចធ្វើការទាក់ទងខាងវប្បធម៌ជាមួយនឹងប្រទេសដទៃទៀតជាច្រើន ដូចជាការប្ដូរនិស្សិត ប្ដូរក្រុមសិល្បៈករនិពន្ធ ក្រុមកីឡា ។ល។ និយាយរួម តាំងពីបានឯករាជ្យមក ដោយសារនយោបាយអព្យាក្រឹត និងរួបរួមជាតិ ប្រទេសកម្ពុជា បានសម្រេចដោយជោគជ័យ នូវការរីកចំរើនយ៉ាងឆាប់រហ័សក្នុងគ្រប់វិស័យទាំងអស់នៃជីវភាពជាតិ ។ ការរីកចំរើននេះ គឺត្រូវបានសម្រេចក្នុងរយៈវេលាមួយដ៏ខ្លី នៅក្នុងភូមិភាគមួយប្រកបដោយការរប៉ោក់របើក ហើយដែលមានបក្សពីរប្រឆាំងគ្នាយ៉ាងស្វិតស្វាញខាងមនោសាស្ត្រ ។

សមិទ្ធិទាំងនោះ គឺជាស្នាដៃនៃប្រជាពលរដ្ឋខ្មែរទូទៅទាំងប្រទេស នៅជុំវិញព្រះប្រមុខរដ្ឋ សម្ដេចព្រះនរោត្តមសីហនុ ដែលទ្រង់ជាព្រះស្ថាបត្យករ និងជាប្រធាននៃចលនាសង្គមរាស្ត្រនិយមផង ។

---

## មិត្តទាំងឡាយ !

បើមិត្តរករឿងសរសេរដើម្បីទស្សនាវដ្ដីយើងពុំទាន់បាន យើងសូមស្នើប្រធានដូចតទៅ :

តើ សហករណ៍សិស្ស ឬសួនចិញ្ចឹមសត្វ ឬក៏សួនបន្លែ នៅក្នុងសាលារបស់មិត្តមានដំណើរបែបណាដែរ ? (បើបានផ្ញើរូបថតមកផង រឹតតែប្រសើរ) ។

# វិជ្ជាពេទ្យ

## រុក្ខជាតិឱសថនឹងជីវសាស្ត្ររុក្ខជាតិ

ប្រែសំរួលដោយ គិម ធី និស្សិតសាស្ត្រាចារ្យ

នៅពេលដែល ឱសថស្ថានបានចាប់កំណើតរីកដុះដាលនៅគ្រប់ទិសទី តាំងពីទីក្រុង រហូតដល់ទីជនបទគៀនកោះដាច់ស្រយាល ការព្យាបាលជម្ងឺ តាមបែបបទបុរាណក៏ត្រូវសាបរលាបវិនាសបាត់បង់ ត្រូវគេបំភ្លេចចោលបន្តិចម្តងៗ ដោយហេតុថា វិធីព្យាបាលពេករបៀបបុរាណច្រើននិយមយកវត្ថុធាតុដើមទាំងដុលមកដាំ មកដុសផឹកតែម្តង ដែលគេយល់ថាគ្មានប្រសិទ្ធិភាព ដូចឱសថពេទ្យដែលគេធ្វើឡើងដោយមានកំរិត និងរបៀបវិធីពិសោធន៍តាមវិទ្យាសាស្ត្រដោយហ្មត់ចត់ត្រឹមត្រូវ ។

ម្យ៉ាងទៀត ការព្យាបាលជម្ងឺតាមរបៀបខ្មែរ ច្រើនមានការផ្សំថ្នាំ មានគ្រណាមតាមជំនឿ ដែលគេយល់ថាមិនសមហេតុសមផល នាំឲ្យអ្នកវិទ្យាសាស្ត្រគេទិះតៀនបំអកឡកឡឺយឲយ ឧទាហរណ៍ដូចជាជីកកាប់យក ឫសឈើ, មែកឈើ, សំបកឈើ ឬ ស្លឹកឈើ ត្រូវមានគ្រណាម មានវិធីតឹងរឹង គឺថាត្រូវយកតែ ឫសឈើ ឬ មែកឈើណា ដែលបែរមុខ ឬ ចាក់ដុះឆ្ពោះទៅទិសនេះ ឬ ទិសនោះ ត្រូវចាំខែនេះ ខែនោះ ឬពេលនេះ ពេលនោះ ទើបជីក ឬ កាប់យកបាន ។ ធ្វើដូចនេះទើបថ្នាំដែលផ្សំនោះមានប្រសិទ្ធិភាពល្អប្រសើរ បើក្រៅពីពេលនោះ ឬទិសនោះ ការយកវត្ថុធាតុនោះមកផ្សំពុំបានលទ្ធផលល្អឡើយ ។

ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការដែលយើងនាំគ្នាបោះបង់ចោលទាំងស្រុងនូវឱសថខ្មែរ នូវការផ្សំថ្នាំរបៀបបុរាណដែលដូនតាយើងបានប្រើប្រាស់ក្នុងការព្យាបាលជម្ងឺតាំងពីសម័យអង្គរយូរណាស់មកហើយនេះ បាននាំឲ្យយើងមានការក្រៀមក្រំសោកស្ដាយជាខ្លាំង ព្រោះថាតាមការពិត បើយើងយកការផ្សំថ្នាំបុរាណមកពិនិត្យពិច័យឲ្យត្រឹមត្រូវមានការពិសោធន៍តាមវិទ្យាសាស្ត្រ យើងនឹងឃើញថា ការផ្សំថ្នាំបុរាណនោះមានប្រសិទ្ធិភាពគាប់ប្រសើរខ្លះដែរ អាចផ្ដល់នូវវិភាគទានយ៉ាងល្អដល់វេជ្ជសាស្ត្របច្ចិមប្រទេសបានផង ។

ដូច្នេះ គឺនៅក្នុងគោលហេតុផលដូចនេះហើយ បានជាមហាប្រទេសចិនប្រជាមានិតបានខ្វល់ខ្វាយយកចិត្តទុកដាក់ស្រាវជ្រាវក្នុងរឿងនេះ ។ ពីឆ្នាំទៅ មានគណៈប្រតិភូចិនមួយក្រុមរួបរួមដោយអ្នកប្រាជ្ញវិទ្យាសាស្ត្រខាងរុក្ខសាស្ត្រ ឱសថការី រុក្ខរត្ន -ល- បានមករុករកទន្ទ្រានព្រៃនៅក្នុងប្រទេសយើង ដើម្បីរករុក្ខជាតិសំរាប់ធ្វើឱសថ ។ នៅប្រទេសយើង របៀបព្យាបាលរោគតាមបុរាណ ដែលមានការពិសោធន៍ជាក់ច្បាស់បានលទ្ធផលប្រសើរជាច្រើន ហើយមានវេជ្ជបណ្ឌិតជាច្រើន ក៏បានទទួលស្គាល់ដឹងឮ ក្នុងរឿងនេះដែរ ។

ការសិក្សាស្រាវជ្រាវយ៉ាងសំខាន់ៗជាច្រើន បាននាំឲ្យយើងបានដឹងថា បុព្វបុរសជាតិយើងមានបំណេះវិជ្ជា ការចេះដឹងក្នុងវិស័យព្យាបាលរោគនេះពិតប្រាកដណាស់ ហើយមានសភាពសមហេតុសមផលជាក់ច្បាស់ណាស់ផង ។ វិធីផ្សំថ្នាំតាមបែបបទដំនៀត្រណាមតាមការពិត គឺគ្រាន់តែជាវិធីផ្លាស់ប្ដូរមធ្យោបាយ ដើម្បីកាច់យកចំណែកនៃដើមរុក្ខជាតិដែលល្អបំផុត ឲ្យបានប្រសិទ្ធិភាពយ៉ាងអតិបរិមាណតែប៉ុណ្ណោះ ព្រោះរុក្ខជាតិនីមួយៗតែងតែផ្លាស់ប្ដូរនូវវត្ថុធាតុ ជាតិគីមី ដែលខ្លួនមានទៅតាមកាលសម័យ និងទៅតាមរដូវ ឧទាហរណ៍ ដូចជាផ្លែម្នាស់ តែងមានរសជាតិផ្អែមយ៉ាងច្រើននៅរដូវក្ដៅ ហើយត្រឡប់ជាមានជាតិជូរច្រើនទៅវិញ នៅរដូវភ្លៀង ។

លើដើមឈើមានផ្លែមួយដើម គេបានសង្កេតឃើញថា ផ្លែទាំងនោះតែងមានគុណភាពខុសគ្នាជានិច្ច ទៅតាមមែកធាងដែលងាកទៅរកទិសនីមួយ ៗ ។ ដោយហេតុដូចពោលមកហើយនេះ ទើបគេត្រូវតែដឹង យល់ឲ្យជាក់ច្បាស់ថា តើទៅពេលណា និងនៅភាគខាងណានៃរុក្ខជាតិ ទើបគេអាចរកសារជាតិ ជាតិគីមី និងវត្ថុធាតុយ៉ាងច្រើន យ៉ាងសំខាន់មកប្រើប្រាស់ផ្សំថ្នាំឲ្យមានប្រសិទ្ធភាពគាប់ប្រសើរបាន ។ គឺក្នុងគោលបំណងដូចពោលខាងលើនេះហើយ បានជាការរកវត្ថុធាតុដើមពីរុក្ខជាតិ ត្រូវតែធ្វើទៅតាមវិធីបច្ចេកទេសតាមបែបបទត្រឹមត្រូវជាក់ច្បាស់ ៗ ឯបែបបទនេះ ក៏ចេះតែក្លាយទៅៗ នៅគ្រប់សម័យកាល រហូតដល់ទៅជាមានសភាពទ្រង់ទ្រាយជាជំនឿ ត្រណម វិធីទៅវិញ ។

យើងគួរដឹងថា ទឹកខ្លែង ដី ធាតុអាកាស និងរុក្ខជាតិផ្សេង ៗ ដែលដុះលាយឡំជាមួយនិងរុក្ខជាតិឱសថទាំងនេះ ក៏ត្រូវតែមានការយកចិត្តទុកដាក់ និងមានការសំគាល់ឲ្យជាក់ច្បាស់ដែរ ។ ដើមរុក្ខជាតិនិងមានគុណភាពខាងឱសថយ៉ាងល្អ តែនៅពេលដែលវាដុះនៅទីដែលវាដុះឯងៗ គឺទីកំណើតរបស់វាពីធម្មជាតិ ។ ដើម « Panax ginseng » ជារុក្ខជាតិយ៉ាងសំខាន់បំផុត មានតម្លៃខ្ពង់ខ្ពស់ ដែលក្បួនវិធីផ្សំថ្នាំចិនត្រូវការណាស់ មានគុណភាពនិងតម្លៃចុះថោកអន់ថយ នៅវេលារុក្ខជាតិនេះ ត្រូវបានគេដាំនៅទីដទៃផ្សេងពីទីកំណើតពីធម្មជាតិរបស់វាដែលបិតនៅក្នុងប្រទេស កូរេ និង ម៉ង់ជូរី ។ ដើម " Derris elleptica " មានគុណភាពល្បីល្បាញខាងមានជាតិ « Rotenone » (ជាតិថ្នាំបាណកឃាត = substance insecticide ) — ដើមរុក្ខជាតិនេះ ដែលដុះនៅប្រទេសម៉ាឡេស៊ី ត្រឡប់ជាមានគុណភាពអន់ថយជាងដើម ដែលដាំនៅភូមិភាគកំចាយ ខេត្រកំពត ក្នុងប្រទេសយើងទៅវិញ ។

ដូច្នេះ សហប្រតិបត្តិការរវាងអ្នកបច្ចេកទេសជាច្រើន មានគ្រូពេទ្យ ឱសថការី អ្នកវិទ្យាសាស្ត្រ គីមី ជីវសាស្ត្រ រុក្ខសាស្ត្រ រុក្ខារក្ស -ល- ច្បាស់ជានឹងធ្វើឲ្យកើតនូវលទ្ធផលយ៉ាងគាប់ប្រសើរ ។

ប្រទេសយើង សំបូរទៅដោយរុក្ខជាតិច្រើនបែបច្រើនយ៉ាងណាស់ ជាហេតុនាំឲ្យយើងអាចធ្វើការស្រាវជ្រាវបានយ៉ាងងាយបំផុត ។ ក្នុងភូគោល និង ក្នុងក្រពញ ដែលមានផ្ទៃដី និង ធាតុអាកាសប្លែក ៗ គ្នា មានលាក់បំបាំងនូវរុក្ខជាតិជាច្រើនដែលយើងនៅពុំទាន់បានរកឃើញនៅឡើយ ។ ការដែលយើងបានលុកលុយ រុករានទន្ទ្រានព្រៃផ្សេងៗពល់ៗ លើក បាននាំឲ្យយើងរកឃើញបានខ្លះ នូវរុក្ខជាតិប្លែកៗ ជាច្រើនដែលយើងបានយកមកទុកជាគំរូ ពិសេស ដូចជាដើម “ Zingiberacées,, ដែលមានគុណភាពយ៉ាងអតិបរិមាណខាងឱសថ ។ គឺនៅក្នុងគោលបំណងសិក្សាស្រាវជ្រាវនិងធ្វើការពិសោធន៍សំខាន់ៗនេះហើយ បានជាសួនរុក្ខជាតិមួយបានត្រូវបង្កើតឡើងនៅក្នុងសាកលវិទ្យាល័យ ក្សេត្រសាស្ត្រ (URSA) ។

កិត្តិយសយ៉ាងធំក្នុងគោលគំនិតនេះ ត្រូវបានទៅលើលោកវេជ្ជបណ្ឌិត នាល - ផ្លុង ដែលជាយូរយារណាស់មកហើយ តែងតែថ្លែងការណ៍រំលឹកដល់អ្នកវិទ្យាសាស្ត្រជាតិយើងជារឿយៗ ឲ្យយកចិត្តទុកដាក់ក្នុងរបៀប និងវិធីផ្សំថ្នាំតាមរបៀបបុរាណ ។ គំនិតរបស់លោកនេះ ត្រូវបានគេយកចិត្តទុកដាក់ជាខ្លាំង ។ ដូច្នេះ គណៈបេសកកម្មយើងក៏បានចាប់កំណើតឡើង រួមដោយឥស្សរជនជាន់ខ្ពស់ជាច្រើនមានវេជ្ជបណ្ឌិត ឱសថការី និងអ្នករុក្ខសាស្ត្រជាដើម ។ ការអាចបានផ្ដល់វិភាគទានអំពីវិជ្ជាខាងរុក្ខសាស្ត្រដ៏ស្ដួចស្ដើងរបស់យើងដល់កិច្ចការស្រាវជ្រាវនេះ បានធ្វើឲ្យយើងមានចិត្តរីករាយយ៉ាងក្រៃលែង ។

★

គណៈកម្មាធិការនាយក សូមជូនពរសព្ទសាធុការដ៏ប្រសើរចំពោះ
មិត្ត គឹម សុនទ្រិញ ដែលទើបនឹងបានរៀបអាពាហ៍ពិពាហ៍ ។
សូមមិត្ត និងភរិយា បានជួបនឹងសេចក្ដីសុខចំរើនគ្រប់ប្រការ !

## សមាសភាពគណៈកម្មាធិការនាយក

| | | | |
|---|---|---|---|
| ១ | មិត្ត | មាស ឌីម | ប្រធាន |
| ២ | – | ព្រុំ សំអារ | អនុប្រធាន |
| ៣ | – | គង់ សុកឃុន | អគ្គលេខាធិការ |
| ៤ | – | អ៊ឹង គីមសេង | អនុលេខាធិការ |
| ៥ | – | ខៀវ កុមារ | អគ្គហេរញ្ញិក |
| ៦ | – | រាម យស្សា | អនុហេរញ្ញិក |
| ៧ | – | ឈាង ហាប់អាន | បណ្ណាល័យ-ទស្សនាវដ្ដី |
| ៨ | – | ធុច រិន | – |
| ៩ | – | កង សារ៉ន | – |
| ១០ | – | សិង ភត់ | – |
| ១១ | – | កែ គីមហួត | ស្នងការគណនី |
| ១២ | – | ទីវ អុល | – |

**មិត្តតំណាង !**

បន្តិចទៀត មិត្តនឹងបានទទួលបញ្ជីជំរឿនសមាជិកដែលយើងផ្ញើទៅជូនពុំខានៗ សូមមិត្តមេត្តាបំពេញ និងផ្ញើមកវិញដោយរួសរាន់ផង ដើម្បីសំរួលដល់ការផ្ញើទស្សនាវដ្ដី ។ ប្រសិនបើមិត្តត្រូវផ្លាស់កន្លែងធ្វើការ សូមមិត្តផ្ញើដំណឹងមកយើងផង ។

សូមអរគុណ !

បានដម្កល់ទុកតាមច្បាប់ត្រឹមត្រូវ

អនុញ្ញាតលេខ ៥៥១ ចុះថ្ងៃទី ១៧ – ១០ – ៦៦

បោះពុម្ពលើកទី ១ ចំនួន ១.៤០០ ក្បាល ។